# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ប៉ូ ជុន ភេទស្រី (នៅរស់) K00675

## ជួបសម្ភាសជាមួយ ប៉ូ ជុន អាយុ៥៩ឆ្នាំ ជាម្ចាស់ប្រវត្តិរូប

## សម័យខ្មែរក្រហមៈ យោធា

## នៅភូមិព្រែកកី ខ ឃុំដង្កោ ខ័ណ្ឌដង្កោ ក្រុងភ្នំពេញ

## ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៤

## សម្ភាសដោយៈ ដាន់ សុដា និង លី សុខឃាង

## ការសម្ភាសន៍លើកទី២

## សរុបៈ ៤៦ទំព័រ

### កាសែតទីមួយ

### ផ្នែក A

យាងៈ ...ដល់ពេលនឹង បើយើងកែប្រែអ៊ីចឹង គេអាចឲ្យយើងធូរស្រាលជាងមុនណា៎ បើយើងអត់កែប្រែ ត្រឡប់ទោស-២១វិញ វីវរហើយ។

ជុនៈ នឹងហើយ ព្រោះថា ចុះមក គេប្រើយ៉ាងម៉េចៗប្រើទៅណា៎ តែខ្ញុំគេអត់សូវប្រើប៉ុន្មានទេ គេច្រើនឲ្យខ្ញុំនៅមើលគេនៅចង្រ្កានអ៊ីចឹងណា៎។ ងាប់ហើយ យប់ឡើងអាអូន អ្ហើយដេកមួយជួរ ពិលគេតូចមួយ គេចុចសួរឈ្មោះៗទៅ។

យាងៈ ពិលសួរឈ្មោះម៉េច?

ជុនៈ ត្រកូលយើងអ៊ីចឹង ឧទាហរណ៍ថា គេចម្រាញ់ប្រវត្តិរូបយើងពីណាមកអ៊ីចឹងណា កូនពិលគេចុច គេសបេញពីមុងៗ ព្រលឹមឡើងយើងចូលជួរ យើងដឹងថាបាត់មិត្តនេះៗហើយ។

យាងៈ អ៊ើ!

ជុនៈ អាអូនឯងដឹងទេ កូនខ្ញុំដែលបាត់ទាំងប៉ុន្មាន ដែលខ្ញុំថាងាប់នៅឯណា? នេះ! បឹងដើងឯកណា៎។ កូនខ្ញុំងាប់នៅនឹងទាំងអស់ ខែភ្ជុំខ្ញុំទៅបង្សុកូល ចូលឆ្នាំខ្ញុំទៅបង្សុកូល។ អូនឯងដឹងទេដូចថា ថ្ងៃនឹងគេយកមកបឹងឡានអ៊ីចឹង គេចំរាញ់មកណា៎ កូននឹងសុទ្ធតែម៉ែឪវាជាប់គុក

ហើយបានគេយកកូននឹងមក ។ ខ្ញុំប្រាប់អូនឯង ក្រណាត់ដែលគេហែកខ្ញុំមុខ ក្រណាត់ប៉ុណ្ណឹង ហើយហែកនឹងក៏ហែកនៅស្មឹងជ្រៅនឹងដែរ ។

យ៉ាង៖ គេហែកចំណាំឬអី?

ថុន៖ គេហែកចងមុខណា ។ នេះ! ហែកប៉ុនៗនឹងទាំងអស់ ។ ដល់ពេលល្ងាចឡើង ប្រហែលម៉ោង៨គេយកមកហើយ ដឹកមកពេញៗឡាន ដល់យកមកគេមិនមកសម្លាប់ចោលនៅបឹងជើងឯកនឹង ដល់ខ្ញុំបែកភ្នំពេញ ខ្ញុំមិនមក មកដល់យួនចូល ។ ខ្ញុំមកដល់ផ្ទះវិញ គេមិនរើសនារីយកទៅរៀននោះ ។

យ៉ាង៖ អ៊ីខ្ញុំសុំសួរបន្តិចអាកន្លែងដែលគេចុចពិលយកអ្នកដែលមានប្រវត្តិរូបអត់ល្អពេលយប់នឹង គេធ្វើឡើងរាល់យប់ ឬក៏?

ថុន៖ រាល់តែយប់នឹងណាំ ។

យ៉ាង៖ ហើយមួយយប់ប៉ុន្មាននាក់ទៅ?

ថុន៖ ទេ! អត់ដឹងប៉ុន្មានៗទេអូន ជួនអីក៏៥ ជួនអីក៏៤, ៣អីអីចឹងតាមតែគេយកទៅ ។

យ៉ាង៖ បាទ! ហើយអ្នកនឹងប្រវត្តិរូបរបៀបម៉េច?

ថុន៖ អត់ដឹង ។ ចុះនៅអាពត អូនឯងទៅជជីកសួរអីគេ ដឹងតែថា គេឲ្យយើងទៅនឹងទៅៗ ។

សុជា៖ អានឹងដោយសារយើងមានជាប់?

ថុន៖ អាពួកយើងជាប់គុកហើយនឹងណាំ មិនមែននៅក្នុងសហជីពទេ យើងជាប់គុកមកហើយ យើងមកក្នុងនេះហើយ ។

សុជា៖ អ៎! ជាប់គុកហើយនឹង គេយកចេញទៅ?

ថុន៖ នឹងហើយ គេយកមកសម្លាប់នៅបឹងជើងឯកនឹងណាំអូន ។ ដល់ពេលហើយ ខ្ញុំមិនទៅរៀននៅវត្តសំបួរមាសនេះ ខ្ញុំគេឲ្យធ្វើប្រធាននារី ។ អូ! ពួកអ្នកនៅសហករណ៍កាច់កុងខ្ញុំសម្បើមណាស់ខ្ញុំប្រាប់ទៅ មកសុទ្ធតែថាយើងនឹងធ្លាប់រស់នៅជាមួយអាពត មានទ្រឹស្តីច្រើនអីចឹងទៅ តាមតែគេថានោះ ដល់ហើយគេចុចខ្ញុំឲ្យទៅរៀននៅវត្តទួលសំបួរភ្លាម ។

សុជា៖ បែក៧៩នឹងអ្ហេស?

ថុន៖ នឹងហើយបែក៧៩ មកដល់ផ្ទះយើងវិញហើយនឹង ។ គេឲ្យខ្ញុំទៅរៀន ដល់ហើយខ្ញុំរៀនកន្លះខែចប់ គេឲ្យខ្ញុំទៅមើលកន្លែងសាកសព កន្លែងវិនាសកម្មនឹងណាំ ទៅដល់ភ្លាមគេយក

អាពតបីនាក់ ទៅដល់គេឲ្យគាស់រណ្ដៅអាហើមទល់ៗអីចេះ ដល់ពេលគេឲ្យគាស់ឡើងមក គរអីចឹង គេឲ្យពួកសិក្ខាកាមទាំងអស់ទៅមើល ។ ទៅមើលខ្ញុំឃើញក្រណាត់នឹងច្បាស់ អាក្រណាត់ហែកនៅទីនោះណា៎ ។ ហើយដល់ហើយ អាដៃនេះគេចងលួសយើងខ្សែភ្លើងណា៎អូន គេចងអីចឹងដូចថា គេមួលម៉ាវើកៗអីចឹងណា៎ អាដៃពីរនឹងក៏មិនទាន់របូតពីលួស អាមុខនេះក៏មិនទាន់ផុត មិនទាន់របូត អាសក់ក្បាលនេះក៏នៅ ខ្ញុំនៅឃ្លូវបានអីចេះ ។

សុជា: នឹងជាកូនរបស់អ៊ំ?

ថុនៈ មិនដឹងទេ តែសន្និដ្ឋានថាកន្លែងនឹងហើយ អត់មានចំណាំអីទាំងអស់ តែសន្និដ្ឋានថា ខ្ញុំក៏ជាប់គុក គេក៏ជាប់គុក គេយកកូនគេមក កូនខ្ញុំក៏អាចនៅនឹងដែរ ខ្ញុំសន្និដ្ឋានថាអីចឹងតែម្ដងទៅ ដល់ហើយខ្ញុំសន្ទប់បាត់ ។

យានៈ ប៉ុន្តែ អាចំណាំអាស្អីចងបាន?

ថុនៈ នឹងហើយគ្រាន់តែចំណាំថាក្មេងកាលពីខ្ញុំនៅទីនោះ គេចងអាក្រណាត់នឹង ក្មេងតូចៗនឹងណា៎ អើ! ហើយកូនខ្ញុំកាលពីបែកអាពត កូនខ្ញុំមីបងវាឆ្នាំវក ប្រហែលជា១៣, ១៤ឆ្នាំ ហើយអាតូចៗនឹង តែមិនដឹងវាស្លាប់ឯណាទេ តែខ្ញុំចេះតែបង្សុកូលកន្លែងនឹងទៅ ។

សុជា: តែដឹងថាគេយកមកហ្នឹង?

ថុនៈ នឹងហើយ អត់ខុសពីនឹងទេ ។

សុជា: អ៎! ខ្ញុំទៅឃើញក្រោយដែរ នៅហ្នឹងឃើញខោអាវអីនៅសល់គេដាក់ខោអាវដែរ ។

ថុនៈ មានៗ អាពេលខ្ញុំទៅមើលនឹង គេកំពុងតែស្រង់មកហើយណា៎អូន អាពតចូលកាយយកមកដាក់ កាយបោះដាក់ហើយនឹង ហើយដែលលួសដែលខ្ញុំថា ដៃនឹងវានៅជាប់លួសនឹងនៅឡើយនឹង មានទាន់របូតឯណា គេមួលមួយវើកៗ ដូចថាក្មេងនោះ គ្នាមានអីអូន អូនឯងឃើញលលាដ៍ប៉ុណ្ណេះក៏មាន ប៉ុណ្ណោះក៏មានអូន ។

សុជា: បើនិយាយទៅអានឹងវាហាក់ដូចជាការសម្លាប់នឹងមានការកំណត់ទុកមួយថា អ្នកណាដែលត្រូវគេយកទៅសម្លាប់ អ្នកណាដែលត្រូវគេបញ្ជូនមកដាក់គុកនឹង ។ ហើយដូចអ៊ំ ប្ដីអ៊ំអីចឹងមូលហេតុដើមមកដោយសារ ប្ដីអ៊ំគាត់នៅធ្វើការនៅខាងឋាមពលអីនឹង ហើយដល់ពេលប្ដីអ៊ំនឹង ខ្ញុំសន្និដ្ឋានថា ប្រហែលជាគាត់នឹងជាប់ខ្សែពីខាងលើៗមក ។

ថុនៈ វាមិនទេអូន ឧទាហរណ៍ថាយើង៧៥ យើងមិនអ្នក១៧សុទ្ធសាធ ។

សុជាៈ នឹងហើយ ។

ថុនៈ ដល់ពេលគេអ្នកដឹកនាំយើងទៅនេះ ដល់ពេលគេសួរថាអ្នកណាអ្នកនាំយើងចូលបដិវត្តន៍ យើងថា រយៈរបស់ កុយ ធួន ហើយ កុយ ធួន វាមិនក្បត់មុនគេ ទៅអស់ ។ អាអូនមិនដឹង អាអូនឯងទៅសួរអ្នកណាដែលដឹងជិតទាន់អាពតណា៎ ក្បត់មុនគេបង្អស់គឺ កុយ ធួន នឹងឯង ។ ដល់ កុយ ធួន ក្បត់ គេយករយៈ កុយ ធួន សិន ឃើញទេ គេយកម៉ាជាមពល ព្រោះជាមពលដែលខ្ញុំចូលនឹង កុយ ធួន នឹងអ្នកនាំចូល តែមិនមែន កុយ ធួន ផ្ទាល់ទេ ឈ្មោះ តាប៉ិន ។

សុជាៈ ប៉ិន នឹងត្រូវជាយ៉ាងម៉េចជាមួយ កុយ ធួន?

ថុនៈ ប៉ិន នឹងមិនដឹងជាអនុ កុយ ធួន មិនដឹងទេ តែគ្រាន់ថាគេនៅកាន់កាប់កន្លែងយើងនឹងណា៎ គេអ្នកនាំខ្ញុំចូល ខ្ញុំសួរគេថាឈ្មោះ តាប៉ិន ។ ខ្ញុំទូចសុំគេមកផ្ទះណា៎ គេថា ចាំជួបអង្គការ ខ្ញុំសួរថាអង្គការនឹងនៅឯណា ខ្ញុំចង់ជួបអង្គការដើម្បីសុំគេមកផ្ទះ មកជួបម៉ែឪខ្ញុំនោះ ដល់ពេលនេះ បាន តាប៉ិន នឹងគាត់ប្រាប់ខ្ញុំថា នែ! មិត្តនារី អង្គការគឺសមូហភាព បើគេឲ្យមិត្តឯងទៅបានទៅ បើគេមិនឲ្យមិត្តឯងទៅ មិត្តឯងក៏មិនបានដឹងដែរ បានខ្ញុំដឹងថា អូ! អង្គការគឺសមូហភាពទេអីចឹង ។

សុជាៈ ចុះប្ដីមីង ហេតុអីបានជាទៅទាក់ទងជាមួយនឹង តាប៉ិន នឹងបាន?

ថុនៈ កំពុងតែថានឹង យើងយកបានឡានមួយទៅជាមួយពួកម៉ាក់គាត់នឹង បានអាកាំមីញ៉ូងមួយថ្មីច្រើនចេញទៅនឹង ដល់ចេញទៅ គេមិនជិះឡានជាមួយយើង គេយកទៅតែម្ដងទៅ ។

សុជាៈ តាប៉ិន នឹងគាត់អ្នកយកឡានជាមួយប្ដីមីងនឹង?

ថុនៈ មិនទេ ឈ្មោះ រុម ទេ ។

សុជាៈ ហើយ រុម នឹងស្គាល់ ប៉ិន នឹង?

ថុនៈ រុម នឹងក៏មិនស្គាល់ដែរ មិនស្គាល់ដូចគ្នា ។

សុជាៈ ចុះប្ដីអ៊ំ និង រុម ហ្នឹងក៏មិនដែលស្គាល់ ប៉ិន ហ្នឹងពីមុនមក?

ថុនៈ អត់រលីងឆេញ អាពតអាណាស្គាល់ ហើយពូ រុម នឹងគាត់ធ្វើការនៅអែរកាំបូឌដែរនឹង គាត់ព្រូឡាន ប្ដីម៉ែមីកល់នៅជាប់ផ្ទះខ្ញុំ ហើយដល់ហើយបានគាត់ថា ប៉ាអាភ័ណ្ឌអើយ យើងបានអីទៅផ្ទះនឹងគេ អត់មានម៉ូតូ តោះ! យើងទៅយករកអូសឡានមួយ លោបាន

ជិះទៅផ្ទះនឹងគេ ពីរនាក់នឹង ចូលទៅអូសមកមែន ឡានថ្មីច្រើនអូន អត់ទាន់បើកទេណា៎ ប្រមៀរប្រេងពីរពុយដាក់ ចេញមកដាក់អីវ៉ាន់តែម្ដង ។ អូ! ខ្ញុំហំណាស់ ដាក់តាំងពីគ្រែ មកផ្ទះទៀតណា៎ គ្រាន់តែអង្ករខ្ញុំប្អូនដប់បាវយកមកផ្ទះ ហើយមកដល់យើងរាល់ថ្ងៃផ្សារដើ ហុយនេះ គេឲ្យយើងបត់ទៅនោះវិញ ។

យាងៈ ពីណាគេឲ្យបត់ទៅ?

ថុនៈ អាពត វាឡើងជិះម្ខាងពីរៗហើយ ទ័ពគេនឹងណា៎ ។

សុជាៈ ដល់ពេលនឹង តាប៊ិន នឹងឡើងជិះដែរ?

ថុនៈ អត់ទាន់ទេ អត់មានស្គាល់ តាប៊ិន នឹងទេ ។

យាងៈ ទៅតែពីរនាក់ រុម នឹងទេ?

ថុនៈ នឹងហើយ ទៅតែពីរនាក់ ពូរុម ហ្នឹង ហើយពួកអាពតហ្នឹង បួននាក់គេជិះអមយើងទៅទេ គេឡើងគោងទូរឡាននឹងទៅ ដល់ទៅដល់ គេបញ្ឈរតែកុងឡានទៅឯណោះ ហើយ ពូរុម ហ្នឹងក៏បត់តាមគេទៅ ទៅដល់គេដាក់នៅកន្លែងពពាលខែលនឹង កន្លែងហាងសាំងថ្មី នៅកន្លែងហ្នឹង កន្លែងដែលខ្ញុំថា យាយទាប នៅនឹងណា៎ កន្លែងនឹងគេឲ្យយើងចុះវិញ ។

សុជាៈ អានឹងនៅខាងព្រែកព្នៅវិញ?

ថុនៈ នឹងហើយ ព្រែកព្នៅហើយ ។

សុជាៈ អ៎! ដល់ពេលគេហៅមីងនៅកន្លែងពោធិចិនតុងនឹងឲ្យមីងបត់ទៅខាងណោះ?

ថុនៈ អើ កាត់ភ្នំពេញថ្មីទៅ មិនទៅឡើងខាងណោះ ។

សុជាៈ អានឹង ឃួញ កប់ស្រូវអីនឹង?

ថុនៈ នឹងហើយ គេមិនមែនទៅដាក់នឹងទេ គេដាក់យើងនៅកន្លែងពពាលខែល កន្លែងហាងសាំង យោធានឹងណា៎ គេយកទៅដាក់យើងនឹងទៅ ហើយដល់ហើយ គេឲ្យប្រពន្ធកូនចុះ គេសរសេរសំបុត្រឲ្យខ្ញុំមួយអ៊ីចឹងទៅ គេថាមិត្តឯងបើគេមកជម្លៀស មិត្តឯងហុចសំបុត្រនឹងឲ្យទៅគេទៅ ។ ដល់គេមក សុំជម្លៀសៗអ៊ីចឹង យើងហុចទៅ គេថា អ៊ុំនឹង មិត្តនឹងគាត់ នៅនឹងទេណា៎ ។

សុជាៈ ពីណាគេអ្នកហុចសំបុត្រឲ្យអ៊ុំ?

ថុនៈ ដែលខ្ញុំថា តាប៊ិន នឹង ។

សុជាៈ អ៊ីចឹងពេលដែលទៅពីកន្លែងពោធិចិតុងនឹងទៅ អត់ស្គាល់ តាប៊ិន នឹងទេ?

ថុនៈ អត់ទេ ។

សុជាៈ មានពួកទាហានខ្មែរក្រហមបីបួននាក់ ឡើងអមឡានមីងទៅ បញ្ជាមីងទៅខាងព្រែកព្នៅនឹង បានជួបជាមួយនឹង តាប៊ិន នឹង?

ថុនៈ នឹងហើយ បានជួបជាមួយទ័ពគេនឹង ។

សុជាៈ ប៊ិន នឹងមីងដឹងថាមានឋានៈអីគេទេនៅក្នុងទ័ពនឹង?

ថុនៈ អត់ទេ ខ្ញុំមិនដឹងថាឋានៈអី ខ្ញុំអត់ដឹងទេ ប៉ុនឹងស្លឹកត្រចៀកខ្វែអ៊ីចេះ មូល ស្លឹកត្រចៀក កំប៉ុតៗអ៊ីចេះ ។

យាងៈ ចុះអ៊ំមានបានមើលលិខិតនឹងគេសរសេរថាម៉េចខ្លះ?

ថុនៈ អត់ អត់ដែលបានមើលអីបន្តិចទេ ព្រោះខ្ញុំអត់ចេះអក្សរដែរ គ្រាន់តែឲ្យកាន់ៗទៅ ដល់តែគេថា អ៊ំជាប្រជាជនជម្លៀសចេញ ខ្ញុំហុចអានឹងឲ្យគេទៅ គេអត់ឲ្យយើងទៅទេ ។

សុជាៈ អ៊ីចឹងពេលដែលគេជម្លៀសប្រជាជនចេញ អ៊ំចូល?

ថុនៈ នឹងហើយ ។

សុជាៈ ចូលបានដោយសារមានលិខិតនឹង?

ថុនៈ អត់ទាន់ចូលទេ យើងថ្ងៃ១៥ណ៎ ថ្ងៃ១៥, ១៦, ១៧ ប្រហែលជាថ្ងៃ២០ បានប្ដីខ្ញុំនឹងគាត់...តែប្ដីខ្ញុំគាត់មិនមែននៅស្ងៀមទេណ៎ អាឡានដែលយើងយកបានមួយទៅ ដឹងទេ គេឲ្យយើងចូលភ្នំពេញវិញ ដឹកថ្នាំពេទ្យយកទៅចាក់គរតែអាកន្លែងនេះនឹង ដែលខ្ញុំថាគេសុំថ្នាំខ្ញុំ ខ្ញុំថាយកទៅ ចេះតែរើសយកទៅ ពួងឯងស្គាល់អី យកនឹងទៅ ។

យាងៈ កាលនឹងពីណាគេដែលឲ្យគាត់ទៅដឹកថ្នាំនៅ?

ថុនៈ អាពួកអាពតនឹង ។

យាងៈ ពួក តាប៊ិន នឹង?

ថុនៈ នឹងហើយ ពួក តាប៊ិន នឹង គេឲ្យយើងទៅដឹក ដូចថាមានអីដឹកមក ដាក់ជ័យភ័ណ្ឌនោះ ដើម្បីដាក់កប៉ាល់មួយដែលចូលមកតាម គេផ្ញើដៃ គេដឹកអីវ៉ាន់ទៅសហករណ៍ក្រោយនោះណ៎ ។ ដល់ពេលហើយ ខ្ញុំក៏ទៅឈប់ហ្នឹងទៅ ដល់ពេលថ្ងៃ ប្ដីខ្ញុំគាត់ចេះតែដឹកអីវ៉ាន់ចេញចូលៗ ហើយខ្ញុំនឹងអ្នកតាមសុំគេមកជួបម៉ែខ្ញុំវិញ ខ្ញុំនឹកឃើញថាដល់ព្រែកព្នៅហើយ ខ្ញុំសុំ

គេ បើគេឲ្យមកស្រុក ខ្ញុំនាំប្ដីខ្ញុំនឹងមកស្រុកវិញ មករកម៉ែខ្ញុំវិញណ៎ា។ ដល់ហើយ ប្ដីខ្ញុំគាត់ថា គេមិនឲ្យទេអូនអើយ ដល់ហើយ ខ្ញុំចេះតែតាមសួរតានឹងនោះ ដល់ហើយមិត្តៗចេះតែប្រាប់ខ្ញុំថា សួររក តាប៊ិន ទៅ ក្រែងលោគាត់អនុគ្រោះឲ្យទៅអីណ៎ា។ ដល់ខ្ញុំចេះតែស្គាល់មុខ តាប៊ិន នឹងទៅ សុំគាត់ បានគាត់ថា អត់មានអង្គការទេ មានតែសមូហភាព គាត់ថាអ៊ីចឹងណ៎ា បានខ្ញុំថា អ៎! អង្គការនឹងសមូហភាពទេអ៊ីចឹង? គាត់ថានឹងហើយ អង្គការនឹងសមូហភាព។ ហើយដល់ខ្ញុំសុំគេអត់បាន ថ្ងៃប្រហែល២០នឹង ប្ដីខ្ញុំគាត់ត្រឡប់ទៅវិញ គាត់យកឡានតូចមួយទៅ។ ប្ដីខ្ញុំគាត់អត់ចេះបើកឡានទេ គាត់រត់តែស៊ីក្លូទេ តែដល់គាត់រៀនឡានប៉ុន្មានថ្ងៃនឹងគាត់ចេះបើកឡាន។ គាត់យកឡានតូចទៅវិញមួយ គាត់ថា ម៉ោះអូនគេឲ្យយើងទៅភ្នំពេញវិញ ខ្ញុំថា អ៎! គេយកទៅណា?

សុជាៈ កាលហ្នុងចេញពីព្រែកឡៅមកភ្នំពេញ?

ថុនៈ នឹងហើយ ដល់ហើយ ណ៎! ខ្មោចហើម អាកន្លែងយន្តតម្បាញសេងថៃខ្មោចកំពុងតែហើមស្ពឹងៗ ប្ដីខ្ញុំគាត់យកក្រមាបាំងកន្លែងទ្វារឡាន អត់ឲ្យកូនឃើញទេ គាត់ថា ប្អូននាំកូនអង្គុយកុំឲ្យអើតមើលណា សុទ្ធតែខ្មោចទេ។ ប្ដីខ្ញុំនឹងក៏នាំខ្ញុំមក អូនឯងដឹងគេនាំមកទុកកន្លែងណាទេ? គេហៅបុយរ៉ូសុសស្ដែម នៅកន្លែងណា? នៅភ្នំពេញយើងម្ដុំវត្តភ្នំនេះ។

សុជាៈ ប៊ីរ៉ូសុសស្ដែម?

ថុនៈ អើ! កន្លែងគេឡើងទៅធ្វើការ គេក្រាលសុទ្ធតែព្រំខ្ញុំប្រាប់អូនឯង។ ហើយខ្ញុំកាលហ្នុងនៅសក់វែងដែរនោះ។ មកដល់នឹងភ្លាម គេយកក្រណាត់ខ្មៅមកឲ្យខ្ញុំពីរដុំណ៎ា ថា នែ! មិត្តនារីឯងកាត់សំពត់ពីរកំប្លេម្នាក់ ហើយកូនខ្ញុំកាលហ្នុងវាពាក់ក្រវិលពុកបង្កងនឹង ពួកមិត្តនឹងហៅវាទៅឈ្លេចសួរណា អ្នកចំរៀងពួកវានោះឈ្មោះ អាឆន។

យាងៈ ឆន នឹងស្អីគេ?

ថុនៈ ឆន នឹងអ្នកចំរៀងវាណា ហើយមីស្រីឈ្មោះអីទេ ខ្ញុំភ្លេចហើយ។ ហើយដល់ហើយទៅវាថា ភ័ណ្ឌមកដើរលេងជាមួយអញ។ តាមការពិត វាហៅកូនខ្ញុំទៅឈ្លេចសួរទេ វាថា អាភ័ណ្ឌ អ្ហែងហៅប៉ាអ្ហែងហៅម៉េចទៅ? ខ្ញុំហៅពុក។ អ្ហឺ! អញមិនជឿផង៏ទេ។ កុមារឯងលាក់នឹង កុមារឯងហៅប៉ាកុមារឯងយ៉ាងម៉េច? ខ្ញុំហៅតែពុកៗ ខ្ញុំអត់ដែលចេះហៅ

ប៉ាផង ។ ហើយចុះម៉ែ? ម៉ែខ្ញុំហៅតែម៉ែៗ ។ ម៉ាក់ទេអ្វី? ហៅម៉ាក់ ម៉ែខ្ញុំធាក់ឆាប់ វាថាអីចឹងណា៎ វាថា ម៉ែខ្ញុំអត់ឲ្យហៅម៉ាក់ទេ គាត់ថាខ្ញុំអ្នកស្រែ ។

យាង: ចុះបើសិនជាហៅប៉ា ឬហៅម៉ាក់វិញ?

ថុន: គេថាកូនយើងអ្នកធ្វើការនៅភ្នំពេញ កូននាយទុន ។

សុជា: ចុះនៅក្នុងគ្រួសារអ៊ំ អ៊ំឲ្យកូនហៅប៉ាម៉ាក់ ឬក៏ហៅឪពុកម្ដាយ?

ថុន: ហៅ ម៉ែ ឪៗ កូនខ្ញុំអត់ដែលចេះហៅយ៉ាងម៉េចទេ ។

សុជា: អ៊ីចឹងកូននឹង គាត់ក៏មិនដឹងមុនថាគេហៅយ៉ាងម៉េចដែរ ដោយសារតែទម្លាប់នៅក្នុងផ្ទះប្រាកដអ៊ីចឹង ឆ្លើយប្រាប់គេត្រង់?

ថុន: ចុះបើខ្ញុំអ្នកស្រែ កូនខ្ញុំមានចេះហៅប៉ាម៉ាក់អីនឹងគេ ហៅតែឪម៉ែៗនឹង ថា មីកាភ័ណ្ឌ ឪឯង មកហើយកូន ដូចថា យើងអត់ទម្លាប់ហៅម៉ាក់ ប៉ាអីនឹងគេនោះ ហើយសមត្ថភាពយើងវាមិនសមហៅម៉ាក់ប៉ាមែន ព្រោះយើងអ្នកស្រែនោះ ។

សុជា: អ៊ីចឹងមីងខ្លួនឯង មីងដឹងថា ចូលជំនាន់អាពតឆ្នាំ៧៥ ថ្ងៃ២០, ២១នឹង មីងដឹងថា ប៉ុលពត មានគម្រោងការចាប់ឬក៏ធ្វើបាបអ្នកដែលមានវណ្ណៈភាពមូលធន អ្នកធ្វើការជំនាន់លន់ នុល អីនឹងមែនអ្អេស បានមីងដឹងថា ឈ្មោះ ឆន ដែលធ្វើសិល្បៈនឹងហៅកូនមីងទៅសួរ ដើម្បីឲ្យកូនមីងនឹងឆ្លើយថាមីងនឹងជាអ្នកមូលធន អ្នកមានអីនឹងណា៎ ។

ថុន: អត់ដឹងទេ តែកូនខ្ញុំវាទម្លាប់អ៊ីចឹងតែម្ដង សួរថា ប៉ាឯងធ្វើអីកាភ័ណ្ឌ ថារត់ស៊ីក្លូ ។ រត់ស៊ីក្លូមែនអ្អេស? រត់ស៊ីក្លូមែនប៉ាខ្ញុំ ។

សុជា: ចុះពេលហ្នឹង រុម នឹងទៅជាមួយមីងទេ?

ថុន: រុម ទៅជាមួយខ្ញុំ តែដល់ពេលកូនគេហៅប៉ាម៉ាក់ៗ កូនគេអ្នកនៅស្អាង ពូរុម នឹង បាត់ពីខ្ញុំតាំងពីនៅព្រែកឆ្លៅទៅមិនដឹងគេយកទៅណា ។

សុជា: ឮហៅពាក្យនឹងអ្អេស?

ថុន: មិនហៅពាក្យនឹងទេ តែបែកគ្នាពីត្រឹមនឹងទៅ មិនដឹងគេយក ពូរុម នឹងទៅណាវិញទៅ ព្រោះកាលអាពត អាណាទៅហ៊ានសួរគេអាអូនអើយ ។ ដល់ហើយបាត់ ពូរុម នឹងមិនដឹងបាត់ទៅណាទៅ ។

យាង: ចុះពេលគ្រួសាររបស់អ៊ំទៅដឹកថ្នាំនៅភ្នំពេញ គាត់ទៅជាមួយពីណាគេ? ទៅជាមួយ តាប៊ិន នឹងដែរ?

ជុន: ទៅជាមួយអាពួកកូនចៅគេនឹងណា៎ គេនៅតែក្នុងនោះទេ។ គេឲ្យតែគ្នាគេទៅទេ យើងមិនអាចទៅណាបាន យើងគ្រាន់តែដឹងថា យើងបើកឡានហើយដាក់ជាមួយគេមកវិញ ឡើងចុះៗជាមួយគេទេ គេម៉ិចនឹងឲ្យយើងទៅណាម្នាក់ឯងបាន។

យាង: មានសួរថាគាត់ទៅដឹកនៅកន្លែងណា?

ជុន: ដឹកនៅភ្នំពេញ ឲ្យតែជ័យភ័ណ្ឌគេឲ្យដាក់កន្លែងណា ទៅដាក់នៅកន្លែងនឹងទៅ អត់មានហ៊ានទៅណារួចពីគេ។ ដល់ពេលបន្តិចបានគេឲ្យប្ដីខ្ញុំទៅកាន់ឡានផ្សេងណា៎។

យាង: កាន់ឡានអីគេវិញ?

ជុន: ឡានសាំង។ មួយខែគេឲ្យទៅកំពតម្ដង ដឹកប្រេងទៅរោងចក្រចក្រីទីងនោះ។

យាង: អ៊ំ! គេដឹកពីណាទៅណា៎?

ជុន: ដឹកពីឬស្សីកែវ។ មួយខែបានទៅតែមួយជើងទេឡាននឹង បាត់ដំបង ទន្លេបិទ ដឹកទៅដល់ឯណាណា៎ ផ្លូវយើងទៅក្រចេះនោះ អាភ្នំខាងនេះនោះ។

យាង: កាលហ្នឹងគាត់នៅក្រោមបញ្ជា តាប៊ិន នឹងដដែលអ្ហេស អាពេលដឹកសាំងនឹង?

ជុន: ប្ដីខ្ញុំនឹង?

យាង: បាទ!

ជុន: ចុះយើង១៧ តែគេកំពស់នេះនឹង ក៏គេនៅលើដែរ ប្ដីខ្ញុំខ្លាចគេចង់ងាប់។

សុជា: យើងដឹងតែដឹកសាំងឲ្យគេទៅ?

ជុន: នឹងហើយ បញ្ជាគេឲ្យទៅណា យើងទៅនឹង។

សុជា: គាត់ធ្លាប់ទៅដល់កំពង់ចាមនឹង ទៅញឹកញាប់ទេ?

ជុន: គេឲ្យតែមួយខែមួយជើង។

សុជា: ហើយទៅកំពតនឹងអីចឹងដែរ?

ជុន: នឹងហើយ មានប្រធានគេនាំទៅ មិនមែនគេឲ្យយើងទៅឯងទេណា៎ មានខ្សែឡានគេត្រឹមត្រូវណា។

សុជា: មានគេចេញម្ដងប៉ុន្មានគ្រឿង?

ថុនៈ ចេញប្អូនដប់គ្រឿងអីចឹងទៅ ស្រេចនឹងគេកុម្មង់យើងឲ្យទៅ ទៅៗ ។

សុជាៈ ហើយសាំងនឹង បើនិយាយទៅដូចដឹកយកទៅដាក់រោងចក្រ ដាក់តាមភូមិភាគ ហើយចុះអាសាំងដែលបានមកនឹង បានមកពីណាមក?

ថុនៈ ដឹកពីកំពង់សោម រទេះភ្លើងដឹកមក ។

សុជាៈ មីងមានដឹងថា សាំងនឹងរបស់ចិនឬក៏របស់អី?

ថុនៈ អត់ដឹង ។

សុជាៈ ហើយមានដឹងថាពីណាគេប្រធានក្រុមដឹកសាំងនឹង?

ថុនៈ អត់ស្គាល់ ភ្លេចអស់រលីង ដូចខ្ញុំថាអីចឹង មានតែឈ្មោះ បងវ៉ាង ឈ្មោះ បងបឿន ឈ្មោះ តាឌុង នឹងគេនៅកន្លែងជាមួយខ្ញុំនឹងហើយ ។

សុជាៈ ចុះកូនមីងដែល ឆន នឹងហៅទៅ កូនមីងឈ្មោះអីគេ?

ថុនៈ ឈ្មោះ សុភ័ណ្ឌ ។

សុជាៈ ស្រីអ្ហេស?

ថុនៈ ចាំ! ស្រី ។ មីស្រីនឹងឈ្មោះមីអីទេ ច្រៀងឲ្យអាពតចំណាប់ ច្រៀងទឹកហូរនាំត្រីក្រាញ់នោះ ខ្ញុំសើចចង់ងាប់ ។

យាងៈ គេច្រៀងយ៉ាងម៉េចខ្លះមីង?

ថុនៈ ច្រៀងបទអី ខ្ញុំសួរថា តាឆន បាទ! អញសួរថា តើក្បាលហុងទឹកនឹងស្អី អញអត់ស្គាល់? ឆ្លួតទេអ្ហី ចាស់ហើយអត់ស្គាល់ ។ ខ្ញុំថា ឆ្លួតភ្លើ អាភ្លើ អញស្គាល់តែត្រពាំងស្គាល់តែស្រះ ហើយអ្ហែងច្រៀងទុកក្បាលហុងទឹក វាស្អីបើអញមិនស្គាល់ អញសួរមើល ។ ក្បាលហុងទឹកនឹង គេទប់ទឹកទុកធ្វើស្រែណាំ ។ អាឆ្លួត អ្ហែងខុសដែរនឹង ស្រុកអញហៅតែត្រពាំង ដីកស្រះ ដីកត្រពាំង ហើយអ្ហែង ទប់ក្បាលហុងទឹក ទឹកហូរត្របាញ់នាំត្រីក្រាញ់ចាក់មកទន្លេឯណា បើអញមិនដែលឮសូរ អ្ហែងច្រៀងអីចឹង ថាសើចជាមួយខ្ញុំណាំ តែនេះវាមកនិយាយលេងជាមួយខ្ញុំហើយ ។ ឈ្មោះមីអីទេ ដៃគូច្រៀងជាមួយខ្ញុំនឹងមីហ្នឹងរាងតឿ តែវាច្រៀងពិរោះណាំ ។ តែនេះវាឌុបកូនខ្ញុំដើរលេងហើយ ។ អូនឯងនៅតូចៗបែបអត់ស្គាល់ជំនាន់អាពតទេ?

សុជាៈ អត់ ។

ថុនៈ ភ្នំពេញណា៎ ថ្ងៃដែលខ្ញុំចូលមកវិញដែលខ្ញុំថាមកនៅក្នុងបន្ទាយបុយវ៉ូគេនឹងណា៎ កន្លែងឡើង គេសុទ្ធតែព្រំក្រាលក្រហម គេបិទទឹក បិទភ្លើងទាំងអស់ ព្ទសូរតែសុីវ៉ែនង៉េៗៗតាមផ្លូវ យើង អាផ្លូវវត្តភ្នំ ផ្លូវអីនឹង អត់មានអីទេអូន គេបិទជិតទាំងអស់ គេប្រើទៀនៗ អូនឯង ដឹងទេ ពួកខ្ញុំនឹង ដូចថាឥឡូវគេឲ្យដាំបាយដប់ខ្ទះអីចឹង គេធ្វើជាមួយពួកមិត្តណា៎ តែគ្រាន់ យើងទៅជួយធ្វើបន្លែគេ គេមិនឲ្យយើងទៅដាំទេ គេខ្លាចបង់ថ្នាំសាប់គេណា សូម្បីបើខ្ញុំសួរ អីចឹងគេឲ្យខ្ញុំសុីមុនណា៎ បើមិនសុីមុនគេមិនសុីទេ គេខ្លាចយើងបំពុលគេសាប់ ព្រោះយើង អ្នក១៧ ដល់ពេលដាំបាយបួនប្រាំខ្ទះអីចឹងទៅ គេសួរប្ដីខ្ញុំថា តាហ៊ិន មានដឹងកន្លែងណា មានត្រីទេ ប្ដីខ្ញុំថា មានអាកន្លែងជិតផ្ទះ សេក សំអៀត ខ្ញុំឃើញអាងត្រីគេនឹង នាំគេមក គេមកអូសយកទៅ ដល់ដាំបាយស្ងោរឆ្អិនអូនអើយ ទះដៃប៉ក់ៗៗ មិនដឹងមកពីណាទេ មនុស្ស ។

យាង: គេដាំបាយបួនប្រាំខ្ទះនឹងសម្រាប់ពួក?

ថុនៈ ពួកមិត្តនឹងវាសុី យើងឈរទះដៃប្រក់ៗៗអីចឹងទៅ មកឡើងផងផឹតមេឃ សុីហើយទៅស្ងាត់ ច្រៀប ។

សុជាៈ ពួកនឹងធ្វើអីគេ?

ថុនៈ ពួកអាពតនឹងណា៎ ។

សុជាៈ តែគាត់ធ្វើការអីគេពួកនឹង?

ថុនៈ ធ្វើអី? ទ័ពដែលគេវាយបាន រំដោះភ្នំពេញយើង គេចូលមកហើយនឹងណា៎ ខ្ញុំនឹងចូលមក វិញជួបនឹងគេនឹងណា៎ ។

យាង: អុំដឹងថាទ័ពនឹងមកពីខាងណា?

ថុនៈ អត់ដឹងទេ ។

សុជាៈ នៅជិតវត្តភ្នំនឹងអ្ហេស?

ថុនៈ នឹងហើយ នៅជិតវត្តភ្នំនឹង ។

សុជាៈ អុំមានដឹងថា ទ័ពនឹងទ័ពរបស់ កុយ ធួន នឹងដែរឬក៏មកពីខាងណា?

ថុនៈ អត់ដឹង ។

សុជាៈ ព្រោះនៅក្នុងភ្នំពេញណា៎ បើតាមខ្ញុំធ្លាប់ទៅសម្ភាសន៍គេនៅកំពង់ចាមដែលជាស្រុកកំណើតរបស់ កុយ ធួន ជាភូមិភាគដែល កុយ ធួន កាន់កាប់គ្រប់គ្រងនឹងណា៎ ពួកដែលនៅខាងជើងវត្តភ្នំទៅស្ពានជ្រោយចង្វារអីចេះណា៎ អានឹងគេទុកទ័ពអ្នកដែលមកពីភូមិភាគឧត្តរ ។

ជុនៈ គេនិយាយនឹងត្រូវហើយ ។ ឧទាហរណ៍ថា គេចែកគ្នា នៅវិមានឯករាជ្យនឹងណា៎ អាមកពីនោះមកដល់ត្រឹមនឹង ឧត្តរទៅ អាចូលមកពីខាងណេះមកអីចឹង នីរតីទៅ អាចូលមកអីចេះ វាជុំជនមុខព្រួញតែខ្ញុំមិនដឹងជាខាងណាៗ ខ្ញុំមិនដឹងទេ ព្រោះខ្ញុំមិនដែលជជីកសួរគេណា៎ណាមួយគេធ្វើការខ្លាំង គេក្តាប់អីចឹង ខ្ញុំអត់ដឹងទេ ។ ខ្ញុំដឹងថាខ្ញុំទៅធ្វើការនៅកន្លែងនឹងបានប្រហែល៤, ៥ថ្ងៃគេឲ្យខ្ញុំមកវិញ ឲ្យទៅនៅមុខយន្តតម្បាញសេងថៃ ។

សុជាៈ អ៊ំនៅបានប៉ុន្មាន នៅវត្តភ្នំនឹង?

ជុនៈ នៅបានបួនប្រាំថ្ងៃនឹង ។

យាងៈ ខ្ញុំសុំសួរបញ្ជាក់បន្តិច ពេលអ៊ំមកពីព្រែកព្នៅហើយ បានមកនៅវត្តភ្នំ?

ជុនៈ នឹងហើយ ។

យាងៈ ហើយពេលអ៊ំនៅព្រែកព្នៅបានរយៈពេលប៉ុន្មានទៅបានមកនៅវត្តភ្នំវិញ?

ជុនៈ នៅប្រហែលថ្ងៃ២០អីមកវិញហើយអូន ។

យាងៈ ថ្ងៃ២០មេសា?

ជុនៈ ថ្ងៃដែលយើងរំដោះបានឆ្នាំ៧៥នឹង ។

សុជាៈ នឹងហើយ ថ្ងៃដែលរំដោះបានថ្ងៃ១៧ មេសា ហើយបានន័យថាអ៊ំនៅព្រែកព្នៅនឹងបានប្រហែលជា៣, ៤ថ្ងៃត្រឡប់មកវិញហើយ?

ជុនៈ នឹងហើយ៣, ៤ថ្ងៃត្រឡប់មកវិញហើយ ។

សុជាៈ ថ្ងៃ២០នឹងឡើងមកវត្តភ្នំ?

ជុនៈ ឡើងមកវត្តភ្នំវិញហើយ នៅនឹងបានបន្តិចគេយកយើងទៅដាក់យន្តតម្បាញសេងថៃវិញ ។

សុជាៈ អានឹងប្រហែលជាប៉ុន្មានថ្ងៃ?

ជុនៈ អើយមិនដឹងប៉ុន្មានថ្ងៃទេអូន ។

សុជាៈ ប្រាំថ្ងៃ វាចូលថ្ងៃ២៥, ២៦នឹង ។

ជុនៈ នឹងហើយ តែនៅនេះទេណា៎ ដល់គេយកខ្ញុំទៅណោះវិញ ទៅនៅកន្លែងនឹងបានពីរបីថ្ងៃ គេថា ដកទៅនៅកន្លែងរោងចក្រប្រេងកន្ទក់នោះ ។

សុជាៈ អានឹងផ្លូវទៅ?

ជុនៈ ផ្លូវព្រែកព្នៅដដែលនឹង នៅនឹងបានពីរបីថ្ងៃ ហ៎! ទៅទៀតហើយ ទៅនៅព្រែកព្នៅនឹងបណ្ដោយ ។ អ៊ំ! មិនទេ នៅនឹងហើយ ចូលមកនៅខាងក្នុង ។

យានៈ ខាងក្នុងណា?

ជុនៈ គេហៅការាស់តាហាក់ នៅព្រែកព្នៅមិនមានផ្លូវមួយបត់ទៅត្បូងបុកទៅមេភ្លើង នៅកន្លែងនឹងបានពីរបីថ្ងៃ ដកទៅទៀតហើយ ។

យានៈ ដកទៅខាងណាវិញទៀត?

ជុនៈ ទៅនៅព្រែកព្នៅនឹងបណ្ដោយ ទៅនៅព្រាត់ប្រាស់គ្នានៅព្រែកព្នៅនឹងតែម្ដង ។

យានៈ ចុះអំកាលនៅព្រែកព្នៅកន្លែងដាំបាយនឹង មានស្គាល់អ្នកណាគេជាប្រធានកងដាំបាយនឹងទេ?

ជុនៈ អត់រលើង ។

សុជាៈ ចុះមានធ្លាប់និយាយលេងអីទេ?

ជុនៈ អត់ ដូចកូនសត្វ ច្រៀបតែម្ដង ។

យានៈ ចុះពេលត្រឡប់ទៅដល់ព្រែកព្នៅវិញ គេឲ្យធ្វើអីទៅ?

ជុនៈ ទៅព្រែកព្នៅវិញ ដាំបាយស្ងូវ ខ្ញុំនៅកន្លែងចុងភៅ ដាំបាយស្ងូវដូចខ្ញុំប្រាប់អូនឯងថា គេឲ្យមើលប្រហុក មើលផ្អកអីចឹងទៅ បានត្រូវមាត់គេស្ដីឲ្យខ្ញុំញយៗនឹង ។

យានៈ ចុះឈ្មោះ ប៉ិន គាត់នៅតែគ្រប់គ្រង?

ជុនៈ អត់ ឃើញតែកាលហ្នឹងទេណា៎ ដល់ខ្ញុំត្រឡប់មកពីភ្នំពេញបាត់ខ្លួនអស់ហើយ លែងដឹងអីអស់ហើយ ។

សុជាៈ ចុះមីងអត់ដឹងថាអ្នកណានៅគ្រប់គ្រងមីងទេ ពេលហ្នុង?

ជុនៈ អត់ទេ ។

សុជាៈ ចុះថាគេហៅទៅៗ ចេញពីកន្លែងមួយទៅកន្លែងមួយចេះតែទៅ?

ជុនៈ ចេះតែទៅតាមគេទៅ ។

សុជាៈ ហើយអ្នកដែលនៅនឹង នៅតែគ្រួសារមីងមួយឬក៏មានគ្រួសារគេ?

ថុនៈ ដោយតែគ្រួសារខ្ញុំមួយទេ ។

សុជាៈ ចល័តរហូត?

ថុនៈ នឹងហើយ ។

សុជាៈ មីងចេញពីវត្តភ្នំមក មកអាកន្លែងរោងចក្រតម្បាញសេងថៃៗ នៅកន្លែងណា?

ថុនៈ នៅឬស្សីកែវនឹង ហួសកាពាស់សាំងសូគីមិច ខ្ញុំនៅកន្លែងនឹងបានតិចដែរនឹង ។

សុជាៈ បានប៉ុន្មានថ្ងៃ?

ថុនៈ ខ្ញុំនៅបានប៉ុន្មានថ្ងៃទេអូន បានបួនប្រាំថ្ងៃៗនឹងអូន ។

សុជាៈ ហើយនៅនឹងគេឲ្យធ្វើអីគេ?

ថុនៈ ដាំបាយឲ្យគេស៊ី ។

សុជាៈ ដាំបាយឲ្យពួកទ័ពដដែលអ្នូស?

ថុនៈ ពីរបីនាក់ ។

សុជាៈ ដាំបាយឲ្យតែពីរបីនាក់ទេ?

ថុនៈ ចា៎!

យានៈ ពីណាគេ អ៊ំមានស្គាល់ទេ?

ថុនៈ ដែលខ្ញុំថាឈ្មោះ តាបុង, តាវ៉ាង, តាមឿន បីនាក់នឹងណា៎ ។

យានៈ បី បួននាក់នឹងគាត់ធ្វើអីដែរ?

ថុនៈ មិនដឹងជាគេធ្វើអីៗតែគេមកស៊ីបាយកន្លែងខ្ញុំ ។ នៅកន្លែងណាក៏ដាំបាយដែរ ។

សុជាៈ ពួកគាត់ធ្លាប់ស្គាល់ពីឈ្មោះ តាប៊ិន នឹងដែរ?

ថុនៈ អត់ដឹងទេ លែងជជីកសួរអីគេហើយ ដឹងតែគេឲ្យមកពីនោះមកនេះ ស្គាល់មុខគេនឹងទៅ គេឲ្យពីនឹងទៅនោះវិញស្គាល់មុខគេតែប៉ុណ្ណឹងទៅ ។

សុជាៈ ចុះប្ដីមីងទៅតាមមីងដែរ?

ថុនៈ ទៅជាប់គ្នារហូតនឹង ។

សុជាៈ អ៊ំ! ដល់ពេលចេញពីកន្លែង តាវ៉ាង, តាមឿន នឹងមក បានមករោងចក្រប្រេងកន្ទក់?

ថុនៈ អត់ទេ នៅជាប់គ្នារហូត ។

សុជាៈ នៅជាប់នឹង?

ជុនៈ នឹងហើយ បីនាក់នឹង គឺទៅណាទៅជាមួយគ្នា ទាល់តែបែកគ្នាពីព្រែកព្នៅនឹងតែម្ដង ។

សុជាៈ អត់ទេ ចង់និយាយថាមឹងចេញពីរោងចក្រសេងថៃនឹងមក មកកន្លែងរោងចក្រប្រេងកន្ទុកទៀត?

ជុនៈ នឹងហើយ ប្រេងកន្ទុកពីរបីថ្ងៃ នៅកន្លែងនឹងដូចថាគេគ្រាន់តែសំចតរកកន្លែងនៅទេណា៎ ហើយដល់ហើយ បានយើងមកនៅក្រោយហាងសាំងឫស្សីកែវឥឡូវនឹង ។

សុជាៈ នៅជាប់នឹងទៅ?

ជុនៈ នឹងហើយ នៅនឹងបានយូរណាស់ ។ បានយូរទៅបានគេទៅបង្កើតប្រេងនៅព្រែកព្នៅ បានគេយកយើងទៅព្រែកព្នៅវិញ ។

យានៈ ហើយទៅអាកន្លែងហាងសាំងគេនឹងអ្នស?

ជុនៈ នឹងហើយទៅហាងសាំងព្រែកព្នៅវិញ ទៅត្រឹមនឹងអស់សិទ្ធិត្រឹមនឹងហើយណា៎ ចប់រឿងត្រឹមនឹង គេយកយើងមកដាក់គុកស្រុកនឹងហើយ អត់មានរឿងអីទៀតទេ រឿងតែមកជាប់គុកតែម្ដង ស-២១តែម្ដងកន្លែងនឹង ។

សុជាៈ ខ្ញុំចង់សួរពេលទៅកន្លែងហាងសាំងឫស្សីកែវនឹងអានឹងនៅតែដាំបាយ ឬក៏ធ្វើការអីដើម្បីឲ្យយើងត្រៀមខ្លួនចេញទៅព្រែកព្នៅនឹង ឬក៏មានធ្វើអីទៀតទេ?

ជុនៈ ដាំតែបាយឲ្យគេស៊ីនឹង ។

សុជាៈ អ៊ើ! ហើយដល់ពេលទៅព្រែកព្នៅនឹង អានឹងនៅយូរ?

ជុនៈ នឹងហើយ ។

សុជាៈ នៅយូរ នៅបានប្រហែលមួយឆ្នាំអីជាងហើយនេះ?

ជុនៈ មួយឆ្នាំជាងហើយអូន ។

សុជាៈ ហើយទៅដល់កន្លែងនឹង បានន័យថាមឹងដឹងអ្នកគ្រប់គ្រងពិតប្រាកដហើយ ព្រោះមឹងនៅយូរអ៊ីចឹង?

ជុនៈ ខ្ញុំអត់ដឹងទេ ដឹងតែថា បងមឿន, បងវ៉ាង បីនាក់នឹង ។

សុជាៈ អ៊ើ! មឿន, វ៉ាង នឹងទៅព្រែកព្នៅដែរ?

ថុនៈ នឹងហើយទៅ ទៅជាមួយគ្នាទាំងអស់នឹង ទៅទាល់បែកគ្នាមកជាប់គុកទាំងអស់គ្នានឹងតែម្ដង ។

សុជាៈ មឿន, វ៉ាន នឹងជាទ័ព ប៉ុល ពត ដែរ ឬក៏ជាអ្នក១៧?

ថុនៈ ប៉ុល ពត ទ័ពចំហើយនឹង ។

សុជាៈ គាត់មានឋានៈអីដែរ?

ថុនៈ ដឹងថាឋានៈគេក្តាប់យើងនៅមន្ទីរនឹងតែម្ដង ។

យានៈ មន្ទីរអីគេ?

ថុនៈ កន្លែងឋាមពលនឹង ក្រសួងឋាមពលនឹង ។

សុជាៈ អ៊ីចឹង តាវ៉ាន, តាបុន គាត់អ្នកគ្រប់គ្រងកន្លែងឋាមពលនៅព្រែកព្នៅនឹង?

ថុនៈ នឹងហើយ ទៅសួរ តារិទ្ធ ទៅ ។

យានៈ ឥឡូវខ្ញុំសុំសួរកន្លែងអំយាមឃុំងប្រហុកណា៎ ពេលនឹងអ៊ំបានជួប តាវ៉ាន់ រិទ្ធ ផ្ទាល់?

ថុនៈ ឥឡូវនិយាយថាអ៊ីចេះអូន ធម្មតាអ្នកធំគេមិនសូវស្គាល់យើងទេ ចំពោះអ្នកតូចទេ ដែលយើងចាំមើលគេ ទោះបីឥឡូវនឹងក៏ដោយ អូនឯងថាគណៈស្រុកស្គាល់យើងអ្ហី តែយើងតើស្គាល់មុខគេ ឧទាហរណ៍អ៊ីចឹងណា៎ ។ ហើយឥឡូវដូច តារិទ្ធ អ៊ីចឹងគេមិនគ្រប់គ្រងនៅក្រសួងពាណិជ្ជកម្ម ហើយគេចុះមកមើលយើងណា៎ គេមិនស្គាល់យើងទេ តែយើងស្គាល់គេ ថានឹងហើយ តារិទ្ធ ដូចខ្ញុំនិយាយលេងថា ណ៎! មើលអ្នកទោសមកហើយ ឃើញទេគេដើរមក កាំភ្លើងគេភ្ជកមុខពីរក្រោយពីណា ។

យានៈ ពួកអង្គរក្សគេនឹង?

ថុនៈ នឹងហើយ ។ ពួកមិត្តមើលអ្នកទោសមកហើយ ។ គេថា អឺ! អ្នកទោស ។ អើ! មើលអញដើរ ដែលអាណាស្ពាយកាំភ្លើងតាមអញម្ដងអ្ហា មើល មានតែគេ ឃើញទេ ។ តែចំពោះគេមិនស្គាល់យើងទេ ព្រោះមនុស្សវាច្រើន ប្រពន្ធតែកុងឡានច្រើនណាស់នៅជាមួយខ្ញុំនោះ ។

សុជាៈ កាលហ្នុងដាក់សុទ្ធតែតែកុងឡានតែម្ដង?

ថុនៈ ចា៎! សុទ្ធតែតែកុងឡានតែម្ដង ។

សុជាៈ ហើយការងារនឹង ចាំតែដឹកសាំងទៅតាមខេត្ត តាមតំបន់ទៅ?

ថុនៈ នឹងហើយ គេឲ្យយើងដឹកប្រេងទៅ យើងដឹងទៅៗ ។ ប្ដីខ្ញុំគាត់មានធម៌ណាស់កាលពី៧៥ ខែប៉ុន្មានទេ ពួកខ្ញុំត្រូវស៊ីនំប័ុងណ៎ា អត់មានបាយស៊ីទេ គេឲ្យយើងស៊ីនំប័ុង ។ ដូចថាឥឡូវនំប័ុងមួយ៥០០អ៊ីចឹង ប៉ិនអូនឯងគេឲ្យមួយកំណាត់ ប៉ិនខ្ញុំមួយកំណាត់ ក្មេងប៉ុណ្ណោះមួយកំណាត់គេពុះជាពីរអ៊ីចេះ គេឲ្យស៊ីប៉ុណ្ណឹង ។

សុជាៈ មួយថ្ងៃ ឬមួយពេល?

ថុនៈ របបមួយពេល ។

សុជាៈ ចុះអត់បាយទេ?

ថុនៈ អត់មានបាយស៊ីទេ ។

សុជាៈ នំប័ុងនឹងបានមកពីណា? ធ្វើឬយ៉ាងម៉េច?

ថុនៈ នំប័ុងគេធ្វើនៅភ្នំពេញនឹង ។ ដល់ពេលហើយកូនខ្ញុំតូច មីមួយនោះ មើល កូនខ្ញុំមានបីនាក់ ឈ្មោះ ជា សុភ័ណ្ឌ, ជា ស្រីភ័ស្ដ តែគេហៅ ខ្មៅ ហើយមីតូចមួយទៀត វាអត់ចេះស៊ី អូនអើយ មាននំប័ុងចំហៀងខ្ញុំដាក់ស្ករសបន្តិច ខ្ញុំឲ្យកូនខ្ញុំជ្រលក់ កូនខ្ញុំស៊ីឡើងស្គម ខ្ញុំបង្រៀនវាស៊ីអាប្រអប់ប័រសល់ពីដើមណាអូន សល់ពីភ្នំពេញ លាបទៅក៏វាអត់ចេះស៊ី ខ្ញុំថាអើយ បងវ៉ាង គិចងាប់កូនខ្ញុំណ៎ា កូនខ្ញុំអត់ចេះស៊ីទេ ។ ហើយអាអូនឯងដឹងថា នំប័ុងអាពតស៊ីជាមួយអី ស៊ីជាមួយសម្លរព្រលិត សម្លរត្រកួន សម្លរកកូរ ដូចគ្នាធម្មតាអ៊ីចឹងទៅណ៎ា ។ ស៊ីទៅដល់ពេលសល់ ខ្ញុំចេះតែហាន់ហាលៗទៅណ៎ា តែអាពួកទៅឡានគេឲ្យបាយស៊ី ប្ដីខ្ញុំថា អូនឯងដាំបាយឲ្យបងឲ្យច្រើនមក គាត់ថា ទៅដល់គាត់ដូចចាហួយយើងអ៊ីចឹង ចែកមួយដុំៗម្នាក់ ប្រជាជនមកសុំស៊ីណ៎ា ។

សុជាៈ បាយនឹង?

ថុនៈ នឹងហើយបាយនឹង គាត់ថា គាត់ទៅ ហើយខ្ញុំខ្ចប់នំប័ុងមួយកញ្ចប់តូចៗៗអ៊ីចឹង ស្ករសបើថាទៅតាមវាលកំពតអីអ៊ីចឹង ចោះ ប្អូនស្រីខ្ញុំអីវ៉ាន់ ខ្ញុំផ្ញើអីមក ដែលបានស៊ីអ្វី ពួកអាពតយកខ្ទេចៗ ។ ខ្ញុំផ្ញើមកប្អូនខ្ញុំតើ ហើយឪពុកខ្ញុំគាត់ឈឺក្បាលណ៎ា ហើយខ្ញុំប្រមូលគេហៅពីដើមថាសំបុកពីងពាងនោះផ្ញើមកពុកខ្ញុំ អាសូរថាពុកខ្ញុំបានមួយគ្រាប់ ។ ខ្ញុំទៅសុំបងវ៉ាងនឹង ខ្ញុំថា បងអើយឲ្យខ្ញុំសុំទៅផ្ទះម្ដងមក គេថាភូមិខ្ញុំងាប់ច្រើនណាស់ ចុះអត់បាយ

នោះអូន គេវាយរបបនោះ ដល់ពេលហើយថា ស្រុក មិត្តជុន ឯង កំពុងតែកើតខ្មែរស កុំទៅអី ចុះវាកុហកយើង ។

## ផ្នែក B

ជុនៈ ...ដល់ពេលខែ៦ តែដូចឆ្នាំ៧៧ ប្តីខ្ញុំនឹងគាត់ដឹងថាពុកខ្ញុំស្លាប់ណា៎ ប្រហែលមួយខែពីរខែ គាត់ទៅរាយការណ៍ប្រាប់ប្រធានណ៎ា ប្រាប់ តាមឿង, តាវ៉ាង, តាជុង ប៉ុន្មាននាក់នឹង ដល់ថ្ងៃល្ងាចខ្ញុំចេះតែឆ្ងល់ ថ្ងៃនេះអង្គការមកលេងផ្ទះអញច្រើនគ្នាម្ល៉េះ ខ្ញុំអត់ដឹងថាគេទៅធ្វើអារម្មណ៍យើង ឪយើងស្លាប់នោះ ស្រាប់តែទៅដល់ថា មិត្តធ្វើអីហើយប្អូនទៅ ខ្ញុំថាហើយៗ ហើយថ្ងៃនេះមានការអីបងឯងមកផ្ទះខ្ញុំនឹង ខ្ញុំសួរអ៊ីចឹងណា៎ ខ្ញុំអត់មានអីទទួលទេ ខ្ញុំមានតែទឹកតែ ខ្ញុំចាក់ទឹកតែឲ្យគេមួយកែវៗម្នាក់អ៊ីចឹងទៅ ។ គេថា មក ចូលមកអង្គុយមក មិត្តជុន អើយ ខ្ញុំសូមចូលរួមមរណទុក្ខ ថាអ៊ីចឹងណា៎ ព្រោះ តាហ៊ន បានរាយការណ៍ប្រាប់ខ្ញុំថា ពុក មិត្តជុន ឯងស្លាប់ ។

សុជាៈ ពីណាគេអ្នកមកប្រាប់អ៊ំថា ឪពុកស្លាប់?

ជុនៈ ពួកអាបងៗនឹង ។

សុជាៈ តាមឿង, តាវ៉ាងអីនឹងអ្ហេស?

ជុនៈ នឹងហើយ ។

សុជាៈ តែប្តីមីងដឹង?

ជុនៈ អត់ហ៊ានប្រាប់ទេ គាត់ខ្លាចខ្ញុំយំ ព្រោះខ្ញុំ ពេលបានចំណីស៊ីឆ្ងាញ់ក៏យំ នឹកម៉ែនឹកឪនោះ ព្រោះនៅម្នាក់ឯងម៉ង់ៗ ។ ពេលហើយ ខ្ញុំអត់មាត់ទេ អង្គុយធ្មឹងអ៊ីចឹង គាត់ថា ព្រលឹមឡើងបងឯងរកអីវ៉ាន់សែនបន្តិចទៅ បងឯងរកម្ហូបរកអីសែនចុះ ខ្ញុំអនុញ្ញាតឲ្យសែនបាន បើអាចធ្វើមាន់សែនបានក៏ធ្វើទៅ ។

សុជាៈ អ៊ំ! ពួកខាងមេគេនឹងគេឲ្យសែន ។

ជុនៈ ពួកអាពតនឹងណា៎ ។ ដល់ហើយខ្ញុំថា ខ្ញុំតូចចិត្តណាស់បង ។ គាត់ថាតូចចិត្តជី? ខ្ញុំថា ខ្ញុំណា៎ តាំងពីកើតពីពោះម៉ែខ្ញុំមក ខ្ញុំមិនដែលបែកម៉ែខ្ញុំមួយថ្ងៃទេ ខ្ញុំនិយាយអ៊ីចឹង តែនៅ

ពេលនេះ ឪពុកខ្ញុំស្លាប់ក៏ខ្ញុំមិនឃើញថាជើងទៅត្បូងទៅជើង តែឈឺរបៀបម៉េចក៏ខ្ញុំអត់ដែល ខ្ញុំសុំបងឯងញយណាស់ ខ្ញុំថាអ៊ីចឹង ។

សុជាៈ គាត់ស្លាប់ដោយសារអីគេ?

ជុនៈ ហើម ពុកខ្ញុំហើមដាច់បាយណា៎ នេះ ប្អូនស្រីខ្ញុំនៅតូចៗជាមួយនេះ មីនេះមួយ ហើយមីពៅមួយ ហើយម៉ែខ្ញុំ ប្អូនប្រុសខ្ញុំគេយកវាយចោលបាត់ទៀតទៅ ។

សុជាៈ ចុះម្តាយ?

ជុនៈ ម្តាយខ្ញុំនៅរាល់ថ្ងៃនឹង អាយុ៨២ហើយតើ ។ ដល់ហើយខ្ញុំថាអ៊ីចឹងទៅ ខ្ញុំអត់មាត់ទេ គេថា អ្ហឺ! បែកគ្នាហើយ ។ គេដឹងថាខ្ញុំនិយាយច្រើនអី ដូចថា ខ្ញុំមួម៉ៅ ខ្ញុំចេះតែថាទៅណា៎ បងវ៉ាង នឹងទៅផ្ទះ ។ ប្តីខ្ញុំថា អូនអើយនិយាយអីសុំកុំនិយាយណា៎ ព្រោះយើងកំពុងតែនៅក្នុងចំណោមគេហើយ គាត់ថាអ៊ីចឹងណា៎ ។ ខ្ញុំថាចំណោមអីចំណោមទៅ ខ្ញុំថាអ៊ីចឹង ។ ដល់ពេលទៅបាត់ ប្តីខ្ញុំដើរបិទទ្វារគ្រិប ខ្ញុំថានៅផ្ទះណា៎ ខ្ញុំថា សង្គមម៉ែវាអីទេ ខ្ញុំថាអ៊ីចឹងណា៎ ប្តីខ្ញុំស្ទុះមកខ្ទប់មាត់ខ្ញុំ ខ្ញុំថា កុំខ្ទប់មាត់ ថ្ងៃនេះហើយងាប់ៗទៅ ថាខ្ញុំមិនដឹងអ្ហឺ ពួកមិត្តនឹងថាវាមិនទៅផ្ទះ ម៉ូតូវាចេញទៅបាត់ៗទៅ យើងទៅតាមដានវា ខ្ញុំថាអ៊ីចឹង ។ ដល់ពេលមួយសន្ទុះ និរសាវាមកហៅខ្ញុំ ខ្ញុំថាសង្គមម៉ែវាអីទេ ម៉ែឪងាប់ក៏មិនដែលឃើញផ្សែងភ្លើង ខ្ញុំជេរអ៊ីចឹងណា៎ ។ ស្រាប់តែមួយសន្ទុះ ខ្ញុំដេកអត់ទាន់លក់ វាមកគោះទ្វារហៅខ្ញុំណា៎ ។

សុជាៈ កាលហ្នឹងពេលយប់អ្ហេស?

ជុនៈ ចា៎! យប់នឹងណា៎ ។ ប្តីខ្ញុំនិយាយពីគាត់ភ័យខ្ញុំឡើងញ័រអ៊ីចឹងណា៎ ។ គាត់ថាបងហាមហើយហាមទៀតថាកុំនិយាយ យើងនៅក្នុងចំណោមគេ ។ ដល់ពេលទៅដល់ ខ្ញុំប្រាប់ថា អ្ហែងចាំបាច់មកហៅអី បើ បងវ៉ាង មិនទាន់ពិសារបាយ នៅក្នុងទូនឹងហើយ ឲ្យគាត់ហូបផងទៅ ។ អត់ទេ គាត់អត់ហូបបាយទេ គាត់ឲ្យមកហៅមីងឯងឲ្យទៅជួបគាត់ ។ ខ្ញុំទៅដល់ភ្លាម មិត្តជុន អ្ហេស? ខ្ញុំថា ចា៎! ថា បងឯងពិសារបាយអ្ហេស? ថា អត់ទេ ។ ហើយគាត់នឹងទំនងថា បើច្បាប់នឹងគេតឹងតែង តែបើថាស្គាល់គ្នាវិញជាងម៉ែវា មិនថាអ៊ីចឹង ។ ស៊ីយប់ព្រលប់ វាឲ្យខ្ញុំទៅរើសប្រពន្ធឲ្យវាទៀត ។

សុជាៈ រើសប្រពន្ធពីណាមក?

ថុនៈ រើសនៅពេទ្យ ។

សុជាៈ អ៊ំ! យកអ្នកពេទ្យអ្ហេស?

ថុនៈ នឹងហើយ ។

សុជាៈ ស្អាតៗអ្ហេស?

ថុនៈ មិនសូវស្អាតណាប៉ុន្មានទេ ។

យាង: ចុះអ៊ំពេលជួប តាវ៉ាង នឹងគាត់និយាយអីខ្លះទៅ?

ថុនៈ ដល់ពេលខ្ញុំទៅដល់ភ្លាម គាត់ថាអង្គុយមក ខ្ញុំទៅអង្គុយនៅជិតគាត់នឹង គាត់ចេញពីគ្រែ គាត់ដេកមក អង្គុយជិតខ្ញុំប៉ាច់ គាត់លែងហៅខ្ញុំមិត្តហើយណា៎ គាត់ថា បង! ខ្ញុំណា៎ ដូចខុទាហរណ៍យើងថា បងឯងបើកភ្នែកគ្រិប បងឯងឃើញអាពត បងឯងជួបខ្ញុំ គាត់ថា អ៊ីចឹង បងឯងជួបខ្ញុំភ្លាម ខ្ញុំដឹងថាបងឯងអ្នក១៧ បងឯងរស់នៅជំនាន់ លន់ នុល បងឯងនៅភ្នំពេញ ខ្ញុំនៅក្រៅ តែខុទាហរណ៍ថាបងឯងបើកខ្វាកមកឃើញខ្ញុំ ហើយខ្ញុំជួបបងឯងប៉ុក ខ្ញុំស៊ីបាយបងឯងតាំងពី៧៥ណាបង វាថាអ៊ីចឹងណា៎ ខ្ញុំទៅណាគឺមានមុខបងឯងទៅកន្លែងនឹង ខ្ញុំទៅដល់សហករណ៍ណាក៏ខ្ញុំអត់ស៊ីបាយដែរ ខ្ញុំត្រឡប់មកស៊ីបាយបងឯងវិញ តែមួយម៉ាត់ដែលបងឯងនិយាយមុិញណាបង ថាសង្គមម៉ែវានឹងណា៎បង គេសម្លាប់បងឯងចោលភ្លាម វាប្រាប់ខ្ញុំថាអ៊ីចឹងណា៎ តែខ្ញុំទុកចិត្តបងឯងដូចម៉ែអ៊ីចឹងណា៎ ។

យាង: វាប្រាប់អ៊ីចឹងអ្ហេស?

ថុនៈ នឹងហើយ វាប្រាប់ខ្ញុំ បានខ្ញុំថា អ៊ំ! វានៅមានមនោសញ្ចេតនាបន្តិចដែរតើ ។ វាថាខ្ញុំដឹងណា តាំងពី តាហ៊ិន ផេះផោះឲ្យបងឯងថា បងឯងកុំឲ្យនិយាយ យើងនៅក្នុងចំណោមគេអី តាគាត់ល្អដែរ បើសិនជាខុសពីត្រចៀកខ្ញុំពួ គឺបងឯងបាត់ខ្លួនយប់នឹងហើយ ។

សុជាៈ បើពួត្រចៀកអ្នកផ្សេង?

ថុនៈ នឹងហើយ តែ វ៉ាង នឹងវាមកស្តាប់ខ្លួនវា ។ វាថាបើក្រៅពីត្រចៀកខ្ញុំគឺបងឯងត្រូវបាត់យប់នឹងហើយ ។ ដល់ហើយអ៊ីចឹង ខ្ញុំអត់មាត់ទេ ខ្ញុំអង្គុយធ្មឹង តវ៉ាក៏ខ្ញុំអត់តដែរ ខ្ញុំអង្គុយស្ងៀម ដល់ហើយវានិយាយអីច្រើន វាថាទៅសម្រាន្តទៅ ស្អែកឡើងធ្វើការទៀត ។ នឹកឃើញថាអ៊ីចេះទេអូន នឹកឃើញថា កូនបីប្តីមួយ យើងទៅប្រហែលជាគេយកទៅទាំងអស់ហើយ នៅតែចៀសផាប់មិនរួច ។

យាន៖ ចុះពេលដែល មីងបិទទ្វារគ្រិបៗ គាត់មាននិយាយប្រាប់មីងអីខ្លះទេ?

ជុន៖ អត់ទេ គាត់និយាយថ្ងៃមុនទេអានឹង ដែលខ្ញុំថាប្តីខ្ញុំអត់ស៊ីបាយពីរបីថ្ងៃណា៎ ខ្ញុំចាប់ច្របាច់ក គាត់ បានគាត់ប្រាប់ខ្ញុំណា៎ៗ គាត់ប្រាប់ដែលថា និស្សិតដែលមកពីស្រុកគេ គេយកទៅសម្លាប់នឹងៗ

យាន៖ និស្សិតមកពីស្រុកណាមីង?

ជុន៖ មិនដឹងមកពីស្រុកណា គ្រាន់តែថាគេឲ្យគាត់មកដឹកណា៎ៗ

យាន៖ ប្រហែលប៉ុន្មាននាក់ទៅ?

ជុន៖ អត់ដឹងទេអូនៗ

យាន៖ គេដឹកមកពី?

ជុន៖ កាលហ្នឹងគ្រាន់តែដឹងថា ចុះពីលើកប៉ាល់ហោះៗ

យាន៖ គេដឹកយកទៅណា?

ជុន៖ គុកទួលស្លែង គាត់គ្រាន់តែប្រាប់ខ្ញុំថា ចុះមកភ្លាមវ៉ាលីសគេដាក់ឡានផ្សេង មនុស្សគេដាក់ឡានផ្សេងណាអូន បងនិយាយប៉ុណ្ណឹងអូនឯងគួរដឹង គាត់ប្រាប់អីចឹងណា៎ គាត់និយាយតែប៉ុណ្ណឹងៗ

សុជា៖ ចុះមីង អារឿងដែលយើងនិយាយត្អូញត្អែរិះគន់ពីរបប ប៉ុល ពត នឹងណា៎ ដែលជាទូទៅ កាលណាយើងនិយាយឮដល់គេផ្សេង គឺគេយកទៅតែម្តង ឬក៏យ៉ាងម៉េច?

ជុន៖ អើ!

សុជា៖ ចុះមានអ្នកដែលនិយាយអីចឹង ត្រូវបានគេយកទៅទេ នៅក្នុងក្រុមជាមួយនឹងមីងនឹងណា៎ៗ

ជុន៖ អត់ទាន់ទេៗ បើនិយាយរួម ខ្ញុំគេយកលើកទីមួយហើយណា៎ តែគ្រាន់តែគេប្រាប់យើងថា បើនិយាយដូចខ្ញុំនឹងណា៎ គឺគេយកទៅវាយចោលហើយ គឺគេមិនទុកទេៗ

សុជា៖ ហើយ វ៉ាង នឹងជាគណៈគ្រប់គ្រងនៅនឹង?

ជុន៖ នឹងហើយៗ

សុជា៖ ហើយ វ៉ាង នឹងមានដែលទៅប្រជុំនៅថ្នាក់លើទេមីង?

ជុន៖ មិនដឹងទេ តែព្រលឹមឡើងការងារយើងដឹងតែដាំបាយស្ងោរ គេទៅណាជារឿងរបស់គេៗ

សុជាៈ ចុះពេលដែល តារិទ្ធ ចុះមកកន្លែងដែលមីងធ្វើការនឹង តារិទ្ធ នឹងមានដែលចុះមកប្រជុំជាមួយនឹងពួក តាវ៉ាង នឹងទេ?

ជុនៈ ខ្ញុំអត់ដឹង ។

សុជាៈ ចុះគាត់ចុះមកយូរទេ តារិទ្ធ នឹង ចុះមកម្តងៗ?

ជុនៈ ចុះមកមួយសន្ទុះៗនឹង ។

សុជាៈ ហើយនិយាយប្រាប់មីងថាម៉េច?

ជុនៈ អត់ គេមិនដែលនិយាយឲ្យយើងទេ គ្រាន់តែគេថាឲ្យយើងអីចឹងណា៎ ។ ដូចថាគេឃើញចង្ក្រានយើងតម្រៀបយើងអុចភ្លើងចោលហៀរអីចឹងណា៎ គេថា មិត្តឯងមើលហ៎ ដុតភ្លើងលេងដៃ មានអុសឯណាឲ្យយើងដុត គេថាអីចឹងឲ្យទៅ យើងនៅក្រោមគេញ៉ាប់ៗចេះតែធ្វើទៅ ហើយគេចូលទៅអើតមើលពាងប្រហុកពាងអំបិលយើងអីចឹងទៅ ហ៎! មើលប្រហុកសុទ្ធតែក្អំរុយ ភ្នំដង្កូវអីអីចឹងទៅ គេថាឲ្យយើងទៅ ។ គេថាអីចឹងហើយ គេទៅវិញទៅ ។

សុជាៈ ចុះ តារិទ្ធ នឹងមក មានដែលនិយាយជាមួយឈ្មោះ វ៉ាង ឈ្មោះ ជុន អីនឹងទេ?

ជុនៈ គេចេះតែនិយាយហើយ គ្នាគេធំៗណាអូន ។

សុជាៈ ហើយមីងដឹងថា អ្វីដែល វ៉ាង នឹងនិយាយប្រាប់មីង គំរាមមីងកុំឲ្យនិយាយរិះគន់របបគេនឹង អានឹងវាជាគោលការណ៍ទូទៅ ដែលគាត់ត្រូវតែប្រាប់ ត្រូវតែប្រមានមីង ឬក៏ជាករណីពិសេសមួយផ្សេង?

ជុនៈ គេនិយាយប្រាប់យើងហើយតើ គេថាបើក្រៅពីត្រចៀកគេណា៎ ផ្លូវនឹងវាហូរទៅហើយ តែគេថា ដូចថាគេបើកភ្នែកគ្រិបគេឃើញខ្ញុំ ខ្ញុំឃើញគេនឹងណា៎ គេថាទុកខ្ញុំដូចម៉ែវាអីចឹងបើការហូបចុក ក្រៅពីខ្ញុំធ្វើវាមិនស៊ីទេ វាខ្លាចគេបំពុលវាងាប់ដែរនឹង ពួកអាអស់នឹង ។

សុជាៈ ចុះនៅកន្លែងនឹង គេមានដែលហៅមីងទៅប្រជុំរៀននយោបាយ ដូចថាបំពាក់បំប៉ន កុំឲ្យយើងមានសតិអារម្មណ៍មិនល្អអីជាមួយនឹងបដិវត្តន៍នឹង មានដែលមានទេ?

ជុនៈ គេប្រជុំជីវភាពនៅសហករណ៍យើងនឹង ។

សុជាៈ ពីណាគេអ្នកប្រជុំ?

ជុនៈ មានប្រធានក្រុមគេម្នាក់ទៅ ស្រីទៅ ។

សុជាៈ ឈ្មោះអីគេប្រធានក្រុមនឹង ។

ថុនៈ មិនដឹងឈ្មោះអីៗទេអូន ភ្លេចអស់ហើយ តាំងពីជំនាន់ហ្នឹងមកភ្លេចអស់ហើយ សុទ្ធតែនារីៗនឹងគេភ្ជាប់ពីលើយើងនឹងណា៎ ដូចថា គេតស៊ូអ៊ីចឹងមក គេមកធ្វើប្រធានយើងទៅ ហើយគេប្រជុំទៅ យើងធ្វើការហូបចុកឲ្យគេមិនស្អាត គេរិះគន់យើងអ៊ីចឹងទៅណា៎ គេអត់ដែលប្រជុំយើងឲ្យហួស ដូចថាចូលនយោបាយអី គេមិនដែលឲ្យយើងប្រជុំទេ ។

សុជាៈ មីងអត់ចាំឈ្មោះគេអ្នកដែលប្រជុំនឹងទេ?

ថុនៈ ចា៎! អត់ទេ មិនចាំទេអូន ច្រើនណាស់កាលនៅព្រែកញ្ញៃនឹងនោះ ។

សុជាៈ អ៊ីចឹងវាហាក់ដូចជាអីចេះ បើតាមខ្ញុំស្តាប់មីងទៅ ដូចថាមីង ឬក៏អ៊ំ ឬក៏អ្នកផ្សេងទៀត ជាស្រីៗ ជានារីដែលនៅកន្លែងឋានពលនឹង ជាប្រពន្ធរបស់អ្នកបើកឡានដឹកសាំងអីនឹង អ៊ីចឹងនារីៗទាំងអស់នឹងគេធ្វើការដូចមីង ជាអ្នកដាំបាយអ៊ីចឹង ឬមានការងារផ្សេងទៀតធ្វើ?

ថុនៈ អត់ទេ សុទ្ធតែដាំបាយទាំងអស់ ។ ហើយប្រពន្ធនឹងមិនមែនពួកនឹង ដូចថា ឥឡូវបែកអ៊ីចឹងណា៎ ខ្ញុំទៅនៅ៧៥ នៅជាមួយវា ៧៦បានគេទៅយកប្រពន្ធគេពីផ្ទះមកណា៎ ដូចថាអូនឯងមានប្រពន្ធមានកូន ធ្វើប្រវត្តិរូបទៅដឹកមក អានោះធ្វើប្រវត្តិរូបទៅដឹកប្រពន្ធយកមក ។

សុជាៈ ហើយអ្នកបើកឡាននឹងជាអ្នក១៧មេសា ដូចមីងច្រើនគ្នាទេ ឬក៏តែមីងម្នាក់?

ថុនៈ បែបច្រើនណា៎អូន ។ តែគេយកមកពីតាមសហករណ៍ណា៎ ។

សុជាៈ អ៊ូ! គេអំពាវនាវមកក្រោយទៀត?

ថុនៈ អើ! នឹងហើយ គេយកមកណា៎ ។

សុជាៈ ចុះពួកនឹង ក្រោយមកពេលដែលគេចាប់ពួកមីង គេមានចាប់ពួកនឹងទេ?

ថុនៈ ចុះឥឡូវបើយើងមកបាត់ហើយ អាណាទៅមើលគេ?

សុជាៈ អត់ទេ មុន មុនដែលគេចាប់មីង?

ថុនៈ លើកទីមួយ ។

សុជាៈ ចាប់មីង ចាប់ដំបូងគេ?

ថុនៈ អើ! លើកទីមួយហើយ អ្នក១៧គេត្រូវយកមុនគេអ៊ីចឹងហើយ ។

សុជាៈ ចុះពួកនឹងអ្នក១៧ដែរនឹង?

ថុនៈ ដឹងគេ១៧ មិនដឹងប៉ុន្មាន អ្នកណាទៅគិតប្រវត្តិរូបគេ អត់ទេ សៀមរាប, កំពង់ធំ, កំពង់ចាម បានខ្ញុំថាគោកត្រប មានតែខ្ញុំមួយទេដែលទៅនោះ ដែលវាស៊ីយទៅជាមួយអាពត ព្រាត់ប្រាសមកដល់រាល់ថ្ងៃនឹងណាំអូន បើសិនជាខ្ញុំមកតាមម៉ែខ្ញុំណាំ ប្ដីខ្ញុំ៧៥ណាំ ដឹកតែទាហានការ៉េងសេទេ ឪពុកខ្ញុំបណ្ដោះខ្ញុំពីភូមិស្វែងភូមិកំណើតខ្ញុំមក ដោយសារប្ដីខ្ញុំពួកម៉ាកទាហានណាំ គេប្រុងមកចាប់ប្ដីខ្ញុំណាំ ពួកអាពតណាំ ដល់ហើយឪខ្ញុំនឹងបណ្ដោះខ្ញុំខែភ្ជុំ ខ្ញុំទើបតែមានកូនមួយទេ ឪខ្ញុំថាមក កូនឯងនៅអត់បានទេ តែនៅកូនឯងមេម៉ាយហើយ មកឪជូន ជូនខ្ញុំមកនៅផ្សារកន្ទួតនេះ ។

សុជាៈ ឆ្នាំណា?

ថុនៈ តាំងពីឆ្នាំ៧៣ណាំ ។

សុជាៈ អ៎!

ថុនៈ ទាហានការ៉េងសេចេញពួកអាពតចូល តាំងពីជំនាន់ណាំឡុងណាំអូន មិនធម្មតាទេ ឪខ្ញុំគាត់ធ្វើការឲ្យគេដល់ពេលហើយ គាត់ដឹងល្បិចគាត់រកសម្លាប់ប្ដីខ្ញុំណាំ ទៅកូន កូន

យាងៈ

ថុនៈ អន្លង់គង ។

សុជាៈ អន្លង់គងនឹងកន្លែងអីគេ?

ថុនៈ ស-២១ ជាប់គុក ។ ហ្នឹងកន្លែងគេថតរូប ធ្វើប្រវត្តិរូបនឹង អូនឯងមិនមើលប្រវត្តិរូបនឹងឃើញហើយ ចាប់ត្រឹមហ្នឹង ។

យាងៈ ហើយហេតុអីបានគេបញ្ជូនមកអន្លង់គងវិញ អ៊ំធ្វើខុសអីដែរ?

ថុនៈ ថាមិនដឹងខ្លួន អត់ដឹងថាយើងធ្វើខុសអីទេ តែគេយកមក ខ្ញុំ, មិត្តថាច ដែលថាប្រពន្ធមិត្តសុខ នឹងណាំ មិត្តមន ។ គេយកបីនាក់នឹង ស្រីៗ ។

សុជាៈ ពួកអស់នឹងជាអ្នក១៧ដែរឬក៏ជាប្រជាជនថ្មី?

ថុនៈ មិនដឹងទេអូនរឿងនឹង គ្រាន់តែថា គេឲ្យបីនាក់នឹងមកតែម្ដង គេថាយកទៅដេរស្បៃក គេយកយើងមកដាក់គុកណាំ ដល់តែគេដាក់ឡានមក គេយកមកទុកនៅនឹង មកដល់គេថតភ្នាម ។ គេថតហើយ គេធ្វើប្រវត្តិរូប គេឲ្យយើងនៅធ្វើការនៅនឹងទៅ ។ ខ្ញុំកើតកូនទើបបានប្រហែល១ខែនឹង មកដល់គេឲ្យអូសទឹកភ្នាម ទាស់ទឹកដោះលែងចេញភ្នាម ។

សុជាៈ ចុះមីងខ្ញុំសួរបកទៅកន្លែងឋាមពលវិញ ពេលដែលមីងឃើញ តាវិទ្ធ មកកន្លែងឋាមពលនឹង មីងនៅតែពុ្ឈោ្មះ កុយ ឃួន អីនៅទេ?

ថុនៈ បាត់អស់ហើយ លែងរំពុកលែងអីអស់ហើយ ។

សុជាៈ ចុះពេលដែល រ៉ាង នឹងនៅ រ៉ាង នឹងមានដែលប្រជុំនិយាយរំពុកថា អ្នកដឹកនាំថ្នាក់លើដូចជា កុយ ធួន ដូចជាអី?

ថុនៈ អត់ទេ ។

សុជាៈ ចុះមីងគិតថា រ៉ាង, មឿង ដែលនៅ តាប៉ិន នឹងខាង កុយ ធួន ឬក៏ខាង តាវិទ្ធ?

ថុនៈ អត់ដឹង គ្រាន់តែដឹងថាអ្នកណាអ្នកនាំយើងចូលបដិវត្តន៍តែប៉ុណ្ណឹងទេ គ្រាន់តែអ្នកនាំចូល គេក្បត់គឺយើងត្រូវ អានឹងដែលអូនឯងសួរថាយើងខុសអីណា៎ ខុសពីអ្នកក្បត់នឹងគេនាំយើងចូល យើងមិនដឹងអីផងនឹងណា៎ ។

យានៈ ខុសដោយសារគេក្បត់?

ថុនៈ នឹងហើយ ព្រោះគេអ្នកនាំយើងចូល ម៉្លោះហើយគេដឹកទាំងយើងទៅ ។

សុជាៈ អ៊ីចឹងប្តីមីងនឹង កាលនាំចូលបដិវត្តន៍ដំបូងខ្សែរបស់ កុយ ធួន?

ថុនៈ នឹងហើយ ។

សុជាៈ តាមរយៈ តាប៉ិន នឹងអ្ហេស?

ថុនៈ នឹងហើយ ។

សុជាៈ ចុះកាលពេលដែលគេចាប់ប្តីមីងនឹង គេមានមកនិយាយអីប្រាប់មីងមុនទេ?

ថុនៈ អត់រលីង ព្រោះគាត់នៅកំពតឯណោះ គាត់នៅដឹកជញ្ជូនសំភារៈចេញពីនោះណា៎ ។

សុជាៈ ចុះមីងអាចនិយាយឡើងវិញអំពីព្រឹត្តិការណ៍ដែលគេចាប់ប្តីមីងណា៎ តើប្តីមីងនឹងដឹងខ្លួនមុនដែរពីការចាប់ខ្លួននឹង ឬក៏យ៉ាងម៉េច មីងអាចនិយាយបានទេ?

ថុនៈ អត់ដឹងទេកាលហ្នុង ខ្ញុំបែកគ្នាឆ្ងាយហើយអូន ។

សុជាៈ អត់ទេ ដូចមីងនិយាយល្ងាចមិញនឹង?

ថុនៈ អ៎! ដឹងគ្រាន់តែថាគេធ្វើប្រវត្តិរូបលម្អិត ។

សុជាៈ ធ្វើប្រវត្តិរូបប្តីមីងនឹង?

ជុនៈ នឹងហើយ គាត់ប្រាប់ណា៎ ។ និយាយរួមទៅ មនុស្សនៅក្នុងនឹង គ្រាន់តែថាយើងគ្មានសិទ្ធិនិយាយណា៎អូន ។

យានៈ ពីណាគេអ្នកធ្វើប្រវត្តិរូបគាត់នឹង?

ជុនៈ មិនដឹងពីណា ។

យានៈ ហើយគេធ្វើនឹងដើម្បីអីគេ?

ជុនៈ មិនដឹងធ្វើដើម្បីអី ។

យានៈ ហើយក្រោយពីធ្វើមក គេយកគាត់ទៅណា?

ជុនៈ ក្រោយពីធ្វើមក គាត់ទៅកំពតបាត់ឈឹងពីខ្ញុំទៅ ។ ខ្ញុំមិនដឹងថាគេយកប្ដីទៅណាផងទេ អត់ដឹងទេ ។ បែបគេយកប្ដីយើងបានប៉ុន្មានថ្ងៃអ៊ីចឹងទៅ បានគេទៅយកយើង ។

យានៈ ពីណាគេអ្នកទៅយកគាត់ទៅកំពត?

ជុនៈ ពួកគេអ្នកទៅដឹកប្រេងនឹងណា៎អូន គេបញ្ជូនយើងទៅអ៊ីចឹងទៅ ។

យានៈ នៅមន្ទីរឃាំមពលនឹង?

ជុនៈ នឹងហើយ នៅឃាំមពលនឹង ។

សុជាៈ ពេលដែលគេចាប់ប្ដីមីងទៅ ដូចមីងនិយាយម្ដងលមិញអ៊ីចឹងថា គាត់ហាក់ដូចជាដឹងមុនថាគេចាប់ខ្សែពីលើៗតៗគ្នាមក?

ជុនៈ នឹងហើយ ដូចគាត់ដឹងអ៊ីចឹង ។

សុជាៈ ហើយមីងកាលហ្នឹង ដូចតាមួយគាត់មកជាមួយខ្ញុំម្ដងលមិញអ៊ីចឹង គាត់និយាយថា អាកន្លែងឃាំមពលនឹង វាហាក់ដូចជានៅចន្លោះក្រសួងពាណិជ្ជកម្មហើយនឹងក្រសួងខស្សរាហកម្ម ព្រោះឃាំមពលនឹង បើគេដាក់ឃាំមពលមួយម៉ាត់វាហាក់ដូចជានៅក្នុងក្រសួងខស្សរាហកម្មទេ បើយើងឥឡូវ តែអាការដឹកនាំចេញចូលចុះឡើងៗអានឹងវាជិតនៅក្នុងក្រសួងពាណិជ្ជកម្មវិញ ។ ពេលនឹងនៅក្នុងក្រសួងខស្សរាហកម្ម មីងដែលឮឈ្មោះ ចេង អន, វ៉ន វ៉េត ទេ?

ជុនៈ អត់ដែលឮទេអូន ។

សុជាៈ បើ កុយ ធួន ដែលឮ?

ជុនៈ នឹងហើយ ដែលឮតែ កុយ ឃួន ។

សុជាៈ កុយ ឃួន នឹងឮពេលណា?

ថុនៈ ពួកអាពេលគេនាំយើងចូលបដិវត្តន៍នឹង ។

សុជាៈ អ៊ីចឹងអាក្រោយពេលដែលមីងទៅនៅ?

ថុនៈ អត់ បែកគ្នាអស់រលីង មិនដឹងគេទៅណាមកណាអីអត់ដឹងទេ បានមកជួប ពួក មិត្តវ៉ាង អីនឹង ជួបត្រឹមនឹងរហូតទល់តែគេយកទៅដាក់គុក ។

សុជាៈ ហើយ វ៉ាង នឹងក៏គាត់មិនដែលនិយាយរំឭកពីឈ្មោះ កុយ ធួន, តាប៊ិន អីនឹងដែរ?

ថុនៈ អត់ដែលនិយាយទេ ។

សុជាៈ ហើយដល់ពេលប្តីមីងគេចាប់មកនឹង?

ថុនៈ មិនដឹងថាគេទៅចាប់ប្តីពីម៉ោងណាផងទេ អត់ដឹងទេ ។

សុជាៈ ចុះតែកុងឡានផ្សេងទៀត មានបាត់ដែរ?

ថុនៈ បាត់បីនាក់នឹង ដែលគេយកពួកខ្ញុំស្រីៗបីនាក់ចេញមកនឹង ។

សុជាៈ ប្តីនារីបីនាក់នឹង គេចាប់?

ថុនៈ មិនដឹងថាគេចាប់ប្តីទាំងបីនឹងទេណា៎ តែគ្រាន់តែថាគេប្រាប់ថា ឥឡូវមិត្តថុន រៀបអីវ៉ាន់ មិត្តមន រៀបអីវ៉ាន់ មិត្តថាច រៀបអីវ៉ាន់ៗ ម៉ាក្នុងម៉ាព្រែកញ្ញានឹងណា៎ គេឲ្យរៀបតែបីនឹងទេ ហើយគេដឹកយើងយកមក ។

យានៈ ទៅអន្លង់គងតែមួយ?

ថុនៈ នឹងហើយ ដឹកមកជាមួយគ្នា ទាំងអស់គ្នានឹង ។

យានៈ ហើយអ៊ីចឹងបានន័យថា គ្រួសាររបស់មីង, ថាច ហើយនិង មន នឹង ត្រូវគេដឹកទៅកំពត ទាំងអស់គ្នាដែរ?

ថុនៈ នឹងហើយ ទៅនឹងទាំងអស់គ្នា ។

យានៈ ហើយដែលឃើញគាត់ត្រឡប់មកវិញដែរ?

ថុនៈ បាត់ទាំងអស់គ្នា ចុះបើឥឡូវខ្ញុំចេញមកពីនឹងហើយ តើយើងទៅដឹងអី រឿងអាណាទៅ អានឹងដឹងហើយ មិនបាច់ចាំសួរទេអាណាទៅណាទៅៗ ។ យើងទៅយើងដឹង គេទៅ គេដឹងហើយ ។

យានៈ ចុះពេលមកដល់ ស-២១ អន្លង់គងនឹង គេធ្វើយ៉ាងម៉េចខ្លះ? គេឲ្យនៅរបៀបម៉េច? គេឲ្យធ្វើការម៉េច?

ថុនៈ គេឲ្យធ្វើការអ៊ីចឹងទៅ ព្រលឹមឡើងចេញទៅ ម៉ោង១១ចូលមកស៊ីបាយហើយទៅ សម្រាក បន្តិចទៅ ចេញទៅទៀតទៅ ស្រេចតែគេប្រើយើងណា៎ អាណាធ្វើខុសគេវាយទៅ អាណា បេះអីគេស៊ីរហេតរហូតគេចង គេវាយអ៊ីចឹងទៅ។ អត់បានទេ តិចណាយើងទៅបេះចេក អីគេស៊ី ទៅបេះផ្លែស្អី ផ្លែឈើទើសក្បាលនឹងតែហ៊ានបេះ ហ៊ានត្រូវ ហ៊ានស្លាប់ហើយ យើងមិនមែនចេះតែស៊ីសេរីបានទេណា៎ របបគេឲ្យបបរស៊ី គេដួសប៉ុណ្ណា យើងស៊ីប៉ុណ្ណឹង។

សុជាៈ ចុះពេលដែលគេយកមីងចេញមកនឹង កូនចៅមីង ហើយនិងកូនចៅមីងមន មីងថាច នឹង គេបញ្ជូនមកជាមួយគ្នាដែរឬអត់ទេ?

ថុនៈ ជាប់តែអាតូចនៅខ្លួននឹង។

សុជាៈ អ៊ីចឹងកូននឹងគេយកទៅណាមុននឹង?

ថុនៈ អត់ដឹង ព្រោះឧទាហរណ៍ថាយើងនៅមន្ទីរវាំងពលនឹងណា៎ យើងមានកូនវ័យពីអាយុត្រឹម ៧, ៨ឆ្នាំគេយកចេញហើយ គេយកទៅនៅមន្ទីរធំ មិនដឹងមន្ទីរធំគេនឹងនៅឯណាទេ យើងអត់ដឹងទេ។ នៅអាពត ដូចថាខែចូលឆ្នាំអ៊ីចឹង គេដឹកកូនយើងឲ្យមកជួបយើងបីថ្ងៃ នឹងទៅ ហួសពីបីថ្ងៃគេយកទៅវិញហើយ ហើយកុមារនៅអាពតកាលណាតែបែកពីយើង ហើយមកនៅជាមួយយើងវិញ វាអត់ចេះនៅទេ វាសុខចិត្តទៅមន្ទីរកន្លែងវាវិញ វាអត់ មានមកនៅជាមួយយើងទេ ហើយខ្ញុំនឹង សុភ័ណ្ឌ នឹងក៏ទៅ កាភ័ស្ត នឹងក៏ទៅ ទៅនៅមន្ទីរ ធំគេអស់ហើយណា៎ ខ្ញុំនៅតែស្រីតូចមួយជាប់នឹងខ្លួនទេ ហើយខ្ញុំកើតមួយទៀត នៅតែពីរ នឹងទេ ហើយអាពីរនោះបាត់ហើយ បាត់ទល់សព្វថ្ងៃនឹងមក។

សុជាៈ នៅក្នុងប្រវត្តិរូបមីងនៅក្នុងនេះដាក់ថា កូនស្រីមួយ ប្រុសមួយ។

ថុនៈ កូនជាប់នឹងខ្លួន។

សុជាៈ អ៊ីចឹងកូនជាប់នឹងខ្លួនពីរនាក់?

ថុនៈ ពីរទៀត កូនខ្ញុំបួន។

សុជាៈ ហើយដែលឈ្មោះ ភ័ណ្ឌ ឈ្មោះ ភ័ស្ត នឹងទៅមន្ទីរបាត់ហើយ?

ថុនៈ នឹងទៅបាត់ហើយ អានេះកូនជាប់នឹងខ្លួនដែលប្រុសមួយ ស្រីមួយនឹងណា៎។

សុជាៈ មីងមានដឹងថាទៅមន្ទីរណាទេ?

ថុនៈ អត់ដឹង គ្រាន់តែគេយកទៅទុកផ្សេងពីយើង។

សុជាៈ ហើយគាត់អាយុប៉ុន្មានពេលដែលគេយកចេញទៅនឹង?

ថុនៈ កូនខ្ញុំធំដែរហើយ ប្រហែលជាអាយុ១៣, ១៤ហើយ ។

សុជាៈ អាយុប្រហាក់ប្រហែលគ្នា?

ថុនៈ កូននឹងបីឆ្នាំពីរ ។

សុជាៈ ១៣, ១៥ឆ្នាំអីនឹងអ្ហេស?

ថុនៈ នឹងហើយ ។ មើលកូនខ្ញុំមីងនឹងកើតតាំងពីឆ្នាំ៦៤ឬ៦៦ទេ គិតតែរដ្ឋប្រហារថ្ងៃ១៨ មីនា កូនខ្ញុំមីនឹងចេះដើរឈរហើយនឹង ។

សុជាៈ អ៎! ៣, ៤ឆ្នាំហើយ ។

ថុនៈ ការប្អូនប្រុសខ្ញុំមួយនៅកន្ទួតនោះ វាការថ្ងៃរដ្ឋប្រហារថ្ងៃ១៨ មីនានឹងតែម្តង កាលហ្នុងកូនខ្ញុំមីនឹងចេះឈរហើយ ។

សុជាៈ ចុះមានដែលទៅលេងកូនទេ?

ថុនៈ អត់ ។

សុជាៈ អត់ដឹងថាទៅណាមកណាទេ?

ថុនៈ គេអត់ឲ្យយើងទៅទេអូន ។

សុជាៈ ចុះគេមានប្រាប់យើងថាកូននឹងនៅ?

ថុនៈ ថានៅមន្ទីរ ។

សុជាៈ ខ្ញុំចង់ដឹងថាមន្ទីរនឹងនៅម្តុំណា?

ថុនៈ ភ្នំពេញ ។

សុជាៈ អត់ដឹងទៀត?

ថុនៈ អត់ដឹងថានៅត្រង់ណាទៀត ។

សុជាៈ ព្រោះមកដល់រាល់ថ្ងៃនឹង តាមដែលខ្ញុំដឹង អារឿងចំនុចដែលយកកូនចេញពីម្តាយទៅដាក់មន្ទីរផ្សេង វាមានអ្នកបាត់អីចឹងតែម្តង អត់ដឹងឪពុកម្តាយទេ ហើយកូននឹងអាយុ១២, ១៣ឆ្នាំនឹង ខ្ញុំលើកឧទាហរណ៍ជាក់ស្តែងដូចរឿង ដាន សុជាត តែខ្ញុំមិនដឹងថា ដាន សុជាត នឹងជាឈ្មោះដែលខ្ញុំត្រូវរកទេណ៎ា តែខ្ញុំទៅសម្ភាស ដាន សុជាត ដែលជាអ្នកចំរៀងរាល់ថ្ងៃនឹងណ៎ា គាត់និយាយថា ពេលដែលនៅក្នុងជំនាន់អាពតនឹងគេយកគាត់ទៅ

ដាក់នៅក្នុងសហករណ៍ក្មេងៗដែរ ហើយគាត់កាលហ្នុងអាយុ១២ ,១៣ឆ្នាំនឹងដែរ ហើយ ដល់ក្រោយមក ពេលបែក៧៩នឹង គាត់ដើរបាត់ ចុះក្មេងអាយុ១២, ១៣ឆ្នាំអត់ដឹងឪពុកម្តាយមុខមាត់យ៉ាងម៉េចទេ មិនដឹងទៅរកឪពុកម្តាយឯណាទេ ហើយបាត់រហូតអីចឹង ហើយខ្ញុំហាក់ដូចជាឆ្ងល់ថា ការដែលយកកូនអ្នកធ្វើការ ឬប្រជាជនយកទៅដាក់សហករណ៍មួយៗនឹង ហាក់ដូចជាអត់ប្រាប់ឲ្យឪពុកម្តាយនឹងដឹង ខ្ញុំគិតថាបើសិនជាប្រាប់ឲ្យឪពុកម្តាយដឹង ឪពុកម្តាយនឹងអាចរកកូននឹងកន្លែងនឹងឃើញហើយ ។

ថុនៈ កូនខ្ញុំ អូនឯងគិតមើល ម្នាក់នៅជាមួយខ្ញុំឈ្មោះ គាំ ប្តីវាឈ្មោះ ឃួន វានៅសៀមរាប នៅដីដែកណ៎ា តែអារឿងនឹងក្រៅទេៗ ដល់ពេលខ្ញុំចេញមកបាត់ កូនខ្ញុំវាមិននៅមន្ទីរ ផ្សេង ដល់ពេលមី ចារីត នឹងមិនដឹងជាវាជាប់គុកដែរឬមិនជាប់ទេ ដល់វាចេញទៅ វាថា ជួបកូនខ្ញុំនៅផ្លូវទៅស្ពឹងឯណាណ៎ា កាភ័ណ្ឌ នឹងណ៎ា ដល់វាចិញ្ចឹមកូនខ្ញុំ យកមកពរកូនវាមក មកដល់កំពង់ឆ្នាំងៗវាថា កាភ័ណ្ឌ កូនខ្ញុំនឹង វាចេញទៅក្រៅ វាមកប្រាប់ថា មីងៗ ខ្ញុំទៅ ជាមួយពូខ្ញុំហើយ ហើយ មីចារីត នឹងក៏មិនដឹងថា ពូងើងមួយណាដែលងើងទៅនឹង ខំយក កូនគ្នាមកហើយនឹងណ៎ាអូនៗ

សុជាៈ កូនមីងនឹងអ្វេស?

ថុនៈ កូនខ្ញុំឈ្មោះ សុភ័ណ្ឌ នឹងណ៎ាៗ

សុជាៈ អ្នកស្គាល់នឹង ជាអ្នកស្គាល់មីងនៅព្រែកព្នៅនឹងទេ?

ថុនៈ ស្គាល់ វាទើបតែងាប់តើៗ ដល់ហើយថា មីងៗខ្ញុំទៅជាមួយពូខ្ញុំហើយ ខ្ញុំខឹងណ៎ាអូនកាល ហ្នឹង បើថាមកជួបគ្នាហើយ សឹងថាចិញ្ចឹមកូនគ្នាមិនចិញ្ចឹមឲ្យជាប់នឹងដៃណ៎ាៗ ថាមីងខ្ញុំទៅ ជាមួយពូខ្ញុំហើយៗ ពូងើងនៅឯណាៗ នោះ ពូខ្ញុំនៅខាងក្រោណ៎ាៗ កូនខ្ញុំនឹងក៏ឆក់ខោអាវ ពីគេនឹង មិតទៅបាត់ទៅៗ

សុជាៈ កូនស្រីនឹង?

ថុនៈ កូនស្រីនឹងៗ

សុជាៈ ឈ្មោះអីគេ?

ថុនៈ ឈ្មោះ ជា សុភ័ណ្ឌៗ

សុជាៈ ចុះ ភ័ស្តុ នោះបាត់ហើយ?

ថុនៈ ភ័ស្តុ នឹងបាត់ហើយ អត់ឃើញទេ។ ខ្ញុំចង់តែផ្សាយរកដែរអូន តែមិនដឹងរកតាមរយៈណា។

សុជាៈ អានេះតាមខ្ញុំជួយមីង តែតាមរយៈទស្សនាវដ្ដីរបស់ខ្ញុំទេណា៎ ហើយចាំមើលខ្ញុំសំណូមពរនៅកន្លែងខ្ញុំនឹង មានទិញម៉ោងវិទ្យុប៉ុស្ដិ៍១០២ អាប៉ុស្ដស្រ្តីណា៎ ទិញម៉ោងផ្សាយពីរឿងរ៉ាវដែលពួកខ្ញុំសរសេរនៅក្នុងទស្សនាវដ្ដីស្វែងរកការពិតនឹង ហើយខ្ញុំនឹងយករឿងរបស់មីងនឹងហើយនឹងឈ្មោះកូនរបស់មីងពីរនាក់នឹងផ្សាយរក ហើយបើគាត់ស្គាល់គាត់ដឹងពីឈ្មោះមីងតាមដំណើរទំនងដែលខ្ញុំយកទៅច្នៃសរសេរនឹង គាត់ពុ គាត់ឃើញ ឬក៏អ្នកដែលគេដឹង គេស្គាល់ គេឃើញទស្សនាវដ្ដីនឹង គេយកទៅប្រាប់កូននឹងបន្ត អានឹងបើសិនជាវាសនាថាកូននឹងនៅរស់ណា៎ តែបើសិនជាអកុសលថា គាត់មិននៅរស់ អានឹងខ្ញុំមិនដឹងថាផ្សាយយ៉ាងម៉េចឲ្យគាត់ដឹងដែរ។

ថុនៈ ខ្ញុំអត់សង្ឃឹមទេអូន តែខ្ញុំគ្រាន់តែថានិយាយនឹងដូចនិយាយកុហកក្នុងចិត្តឯងទេ បើនិយាយរួមខ្ញុំថាងាប់នៅហ្នឹង។

សុជាៈ ងាប់នៅទួលស្លែងនឹងអ្អូស?

ថុនៈ ដើងឯក។

សុជាៈ អានឹងមីងសន្និដ្ឋានថាម៉េច បានថាគេយកកូនមីងមកនឹង?

ថុនៈ ចុះបើយើងជាប់គុក ម្ល៉ោះហើយគេស្រាវជ្រាវប្រវត្តិក្មេងនឹងមក ឧទាហរណ៍ថាម៉ែឈ្មោះអីឈ្មោះ កែប ថុន ចុះឪ? ឈ្មោះ ជា ហ៊ិន ឬ ភោគ ហ៊ិន អីចឹងណា៎ គេមិនយកកូនយើងមក អានឹងខ្ញុំសន្និដ្ឋានខ្លួនខ្ញុំទេណា៎ ធម្មតាមន្ទីរមួយគេមិនស្រាវជ្រាវប្រវត្តិរូប ដល់គេយកមក ឧទាហរណ៍ដូចខ្ញុំថា ដូចមួយឡានៗដែលគេប្រមូលយកទៅអីចឹង ហើយយប់យើងមើលគ្នាឃើញ? ហើយគេយកមក ពេលម៉ោង៦, ម៉ោង៧ ម៉ោង៨ឡើងគេយកទៅវាយចោលអស់ហើយ មិនអស់។

សុជាៈ ចុះអាពេលដែលគេប្រមូលក្មេងមកសម្លាប់នៅបឹងដើងឯកនឹង មីងបានទទួលដំណឹងនឹងពីណាមក?

ថុនៈ ឃើញណា៎។

សុជាៈ ឃើញក្មេងៗនឹង?

ថុនៈ នឹង ។

សុជាៈ ឃើញយ៉ាងម៉េច?

ថុនៈ គេដឹកមក ឡើងណែនៗមួយឡានៗអ៊ីចឹងទៅណា ។

សុជាៈ ពេលនឹង មីងនៅឯណាបានឃើញ?

ថុនៈ នៅកន្លែងស្ទឹងជ្រៅនឹង ។

សុជាៈ ស្ទឹងជ្រៅតាខ្មៅនឹង?

ថុនៈ នឹង ។

សុជាៈ ហើយគេដឹកពីណាមកវិញ?

ថុនៈ មិនដឹងគេដឹកពីណាមក ។

សុជាៈ ឃើញឡាននឹង ក្បាលគេបត់ទៅណា?

ថុនៈ ឡានមកធំៗមកចតនឹង ព្រាតអ៊ីចឹងទៅ ពីមុខផ្ទះយើងនៅនឹង បីបួនអាកាំមីញ៉ុងអាឡាន ឃុបៗនោះ ដាក់ក្នុងនឹងបីបួនទៅ ម៉ោង៨អីគេចេញមក ។

សុជាៈ ចុះមីងដឹងគោលដៅគេចេញមកពីណាដែរ?

ថុនៈ មិនដឹងទេ ដូចខ្ញុំប្រាប់អូនឯងថា ឃើញអាក្រណាត់ចងមុខ ។

សុជាៈ អ៊ីចឹងបានន័យថា ពេលដែលគេដឹកក្មេងនឹងមក មីងឃើញក្មេងនឹងត្រូវបានគេចងមុខ?

ថុនៈ អត់ឃើញទេ តែឃើញដូចថា គេដាក់ឡានឃុបអ៊ីចឹងមក គេចងពីក្រោយណ៎ា ហើយដូចថាចុះក្មេងវាចេះតែញេះញ៉ុះៗៗនៅក្នុងនឹង យើងដើរក្បែរអីឮហើយ យើងដើរទៅមុជទឹកស្ទឹងនោះ យើងឮក្មេងនៅក្នុងនឹងអាញឹកអាញ៉ៅហើយ តែយើងទៅសួរអី យើងហ៊ានសួរមនុស្សដេកចាំតែផាប់ដូចតែគ្នានឹង ទៅចាំបាច់ដឹងរឿងគេអីច្រើន ។

សុជាៈ អ៎! ដល់ពេលមកក្រោយ៧៩នេះ មីងទៅអាកន្លែងបឹងជើងឯកនឹងឃើញលលាដ៍ក្បាល?

ថុនៈ នឹងហើយ ឃើញលលាដ៍ក្បាលអាក្មេងញ៉េចញ៉ាចតូចៗនឹង ដឹងបាត់ហើយ ។

សុជាៈ លលាដ៍ក្បាលក្មេងតូចៗនឹងនៅនឹង?

ថុនៈ នឹង ។ ខ្ញុំទៅបង្សុកូលរាល់តែឆ្នាំ ខ្ញុំអត់ដែលខានទេអូន ។

យាងៈ ចុះអ៊ំ ខ្ញុំសូមសួរបន្តិច ពេលអ៊ំគេបញ្ជូនមកអន្លង់គងនឹង ពីណាគេអ្នកគ្រប់គ្រងនៅនឹង?

ថុនៈ ឈ្មោះតាអីទេ ភ្លេចបាត់ហើយ ។ ចុះពី អាឌុច មក ។

យាន: ឌុច មកពីណាគេទៀត?

ថុន: វាក្មេងឈ្មោះតានឹងណា៎ ។

យាន: ដឹងតែនៅអន្លង់កងនឹង ធំជាងគេ ឌុច?

ថុន: នឹងហើយធំជាងគេ អាឌុច នឹងតែម្តង ព្រោះអូនឯងដឹងទេ លើជាងគេ អាឌុច ដល់យួនចូលមករត់ជាមួយ អាឌុច ទៀត ។

យាន: រត់ទៅជាមួយ ឌុច?

ថុន: រត់ទៅជាមួយ ឌុច មានរត់ទៅណារួច ។

យាន: ចុះនៅនឹង វាមានកង ដូចថា ឌុច នៅលើអ៊ីចឹង វាមានកូនក្រុមគេ?

ថុន: មាន ។

យាន: ចុះមេក្រុមឈ្មោះអី?

ថុន: អ៊ំ! មេក្រុមៗមិនដឹងឈ្មោះអីទេ ក្មេងអស់ហើយ មិនយកចិត្តទុកដាក់ដូចថាចង់បំភ្លេចឲ្យអស់ពីក្នុងខ្លួនរឿងអាពតមួយ មិនចង់ទុក ក្រៅពីប្រវត្តិកូនឯង ។

សុជា: ចុះមីងថាអន្លង់កងនឹងវាចំណុះឲ្យមន្ទីរស-២១អ្ហេស?

ថុន: នឹង ។

សុជា: ហើយស-២១នឹង អ្នកធំជាងគេ ឌុច?

ថុន: ដឹងតែ អាឌុច នឹងតែម្តងអ្នកធំជាងគេ?

សុជា: មីងដែលឮឈ្មោះ ឌុច នឹង? មីងដឹងមុនឬក៏ក្រោយ៧៩?

ថុន: ចាំមើលណា៎ ដូចថាយើងដឹងហើយ យើងមិនមែនដឹងមុនអាពតទេណា៎ តែដល់ក្រោយឡើង អ្នកជាប់គុកស-២១ គេនិយាយថា ប្រធានគុក អាឌុចៗ អ៊ីចឹងតែម្តង ។ ដល់ហើយ ខ្ញុំរត់ យើងអត់ដឹងទេពីដើម នៅក្នុងគុកណា៎ ដល់ថ្ងៃយើងរត់ទៅពេលយួនដេញ ខ្ញុំថាចុះអាប៉ុណាសស្គសតូចនេះ ។

សុជា: តែធ្លាប់ឮឈ្មោះពីជំនាន់ដែលមីងនៅអន្លង់កងនឹងហើយ?

ថុន: អត់ដែល អត់ស្គាល់ទេ ។ គ្រាន់តែថា ចុះយើងម៉េចនឹងរត់ទៅណោះវិញ ។ ចាំមើលគេដឹកខ្ញុំទៅអ៊ីចឹងទៅ មិនដឹងទៅដល់ត្រឹមណា៎ទេ ដឹកយប់ចេញ ស្រាប់តែភ្លឺឡើងគេឲ្យចុះ...

## កាស្សែតទីពីរ

## ផ្នែក A

ថុនៈ ...ប្អូនធម៌មួយនៅនឹង គេសួរថា បង បងឯងស្គាល់ អាឌុច ទេ? ឌុច ណា? អាឌុច ស-២១ នោះ បងឯងអត់ស្គាល់ទេ បងឯងជាប់គុកដែរអត់ស្គាល់ទេ? ខ្ញុំថាជីមិនស្គាល់ បានវាឆខ្ញុំ វាថា អាឌុច នឹងប៉ុណ្ណា? បងឯងដឹង ឆ្លើយមើល? ខ្ញុំថា អាឌុច តូចល្អិត ស វាថា នឹងមែនហើយ ។ បើប្រពន្ធវាខ្មៅខ្ចិចអូន ។

សុជាៈ ប្រពន្ធអ្នកអមលាំង តែគាត់អ្នកកំពង់ធំទេ ។ តែដល់ពេល ឌុច នឹងចេញមកធ្វើបដិវត្តន៍ គាត់អត់ធ្វើនៅកំពង់ធំទេ ចេញមកធ្វើនៅអមលាំងនឹងតែម្តង ។

ថុនៈ ថ្មគោលអ្វេស?

សុជាៈ អត់ទេ អមលាំងនឹងវាមិនមែនថ្មគោលបាត់ដំបងទេ អមលាំងនៅកំពង់ស្ពឺនេះ ។

ថុនៈ ចាំមើលមានភូមិវាណា៎ មានកន្ទុត ដំណាក់កន្ទុត ភូមិត្នោត ភូមិស្អីនឹងមកនៅក្នុងប្លុកនឹង ។

សុជាៈ នឹងវានៅក្នុងស្រុកឱ្ទង ខេត្តកំពង់ស្ពឺណា៎ ។

ថុនៈ នឹងហើយ ខ្ញុំទៅដេកនឹងយូរណា៎ ។ អាឌុច នាំទៅដាក់នៅនឹងយូរណា៎ ។

សុជាៈ មីងខ្ញុំចង់សួរបន្តិច អន្លង់គងនឹងនៅម្តុំណា?

ថុនៈ អត់ស្គាល់អន្លង់គង?

សុជាៈ ខ្ញុំអត់ស្គាល់ បើស្ទឹងជ្រៅ ខ្ញុំស្គាល់ព្រោះផ្ទះខ្ញុំជិតនឹងដែរ ។

ថុនៈ នេះទៅពីនឹងទៅ គេហៅផ្កានេះ ។

សុជាៈ ផ្កា? អានឹងជាប់មាត់ស្ទឹងដែរឬអត់?

ថុនៈ ប៉ាការហើយបានបត់ទៅត្បូងអីចេះទៅ ជាប់មាត់ស្ទឹងមិនអន្លង់គង អាអូនឯងទៅឥឡូវ ពួកអានឹងគេថា អន្លង់គងឥឡូវមានពួកប៊ូល អាណាកាន់ប៊ូលស៊ីម៉ូតូស៊ីអីនឹង ។

សុជាៈ អ៊ូ! ចុះស្ទឹងជ្រៅ?

ថុនៈ ស្ទឹងជ្រៅនៅ ចុះមកវត្តព្រែកឫស្សីនឹង ឆ្លងស្ពាននឹងដើរមកដើងមក ។

សុជាៈ ខ្ញុំធ្លាប់ដើរកាត់ស្ទឹងជ្រៅនឹងដែរ ខ្ញុំធ្លាប់ដើរកាត់បឹងនឹងដែរកាលខ្ញុំនៅតូចណា៎ ។ អ៊ីចឹងស្ទឹងជ្រៅនឹងបើដើរព័ទ្ធមកអីចេះវាចំអន្លង់គងនឹង ។

ថុនៈ ស្ទឹងជ្រៅឯណាដើរកាត់មក?

សុជាៈ  កាត់បឹងមក  មកចំបឹងជើងឯកណោះវិញណា៎ ។

ផុនៈ  អាបឹងជើងឯកនឹងនៅខាងលិចនេះទេអ្ហ៎?

សុជាៈ  នឹងហើយ នៅខាងលិចស្ទឹងជ្រៅ ។

ផុនៈ  ទាល់តែយើងដើរទៅភូមិចេកណា៎ ។

សុជាៈ  នឹងហើយ ។

ផុនៈ  បានកាត់មកបឹងជើងឯកបានណា៎  តែខ្ញុំមិនដែលដើរទេឥឡូវនឹង  តែខ្ញុំធ្លាប់ដើរពេលគេយកក្មេងទៅឲ្យកាប់ព្រៃអីនោះ  ខ្ញុំធ្លាប់ដើរតាមវាទេ ។

សុជាៈ  អ៊ីចឹងបានន័យថា  អានេះវានៅក្នុងប្លុកតែមួយណា៎  តំបន់ជាប់មាត់ស្ទឹងដូចគ្នា ។

ផុនៈ  នឹងហើយ  កាលហ្នុងគេមិនមានកង ។

សុជាៈ  កងយ៉ាងម៉េចទៅ?

ផុនៈ  កងអាពតវាមានកង១១,  កង១២,  កង១៣នឹងកងសេរី  កងសុទ្ធតែមនុស្សដែលគេប្រុងនឹងវាយចោល  ខ្ញុំនឹងនៅកង១៣ហើយនេះ  មនុស្ស១៧ណា៎ ។

យានៈ  កងសេរីនឹងមានន័យថាហូបចុកសេរី?

ផុនៈ  មិនមែនកងសេរីទេ  កង១៣នឹង  កងមនុស្ស១៧ ។

សុជាៈ  ហើយគេឲ្យធ្វើអីគេនៅអន្ទង់គងនឹង?

ផុនៈ  គេឲ្យស្ទូង  គេឲ្យដាំបាយ  គេឲ្យអូសត្រី ។

សុជាៈ  ចុះនៅស្ទឹងជ្រៅ?

ផុនៈ  នៅស្ទឹងជ្រៅ  ក៏គេឲ្យធ្វើអ៊ីចឹង  បាចទឹកដាក់សន្ទូង ។

សុជាៈ  នៅស្ទឹងជ្រៅប៉ុន្មានថ្ងៃបានគេឲ្យមកអន្ទង់គង  ឬក៏នៅអន្ទង់គងមុនស្ទឹងជ្រៅ?

ផុនៈ  នៅស្ទឹងជ្រៅជាប់គុក  នៅអន្ទង់គងទាល់តែយួនចូលមកនឹង ។

សុជាៈ  ចុះនៅស្ទឹងជ្រៅ?

ផុនៈ  នៅស្ទឹងជ្រៅទៅមកៗ  ត្រូវគេដកយើងទៅស្ទឹងជ្រៅដកទៅ  គេយកមកអន្ទង់គងវិញយកមក ។

សុជាៈ  ចុះមីង  អាកង១១,  ១២នេះ  អាកង១១យ៉ាងម៉េច?

ផុនៈ  អាកង១១ដូចថាកងគេលត់ដំបានមិនដឹងអីក៏មិនដឹងរឿងនឹង ។

សុជាៈ នឹងគេឲ្យធ្វើការធួរជាងអ្ហូស?

ថុនៈ អេ! ដូចមិនធួរទេអូន មើលទៅ ។

សុជាៈ តែខ្ញុំចង់ដឹងថា បើកាលណាគេបែងចែកអ៊ីចឹងសភាពនៃការរស់នៅនិងការធ្វើការពីកងមួយទៅកងមួយប្រហែលជាខុសគ្នា, មែនទេ?

ថុនៈ ឃើញតែដើរលូកចូលគ្នាដែរ ។

សុជាៈ តែប្រភេទមនុស្សវិញ កន្លែងនឹងសុទ្ធតែអ្នកទោសអ្នកអស់ មិនអ៊ីចឹងអ្ហូស?

ថុនៈ នឹង ។

សុជាៈ ចុះប្រភេទអ្នកទោសយ៉ាងម៉េចដែលគេចាត់ចូល១១ ហើយអ្នកទោសយ៉ាងម៉េចបានគេចាត់ចូល១២ ហើយអ្នកទោសយ៉ាងម៉េចចូល១៣?

ថុនៈ អានេះពិបាកណាស់អូន មិនដឹងប្រភេទយ៉ាងម៉េចៗទេ ឧទាហរណ៍ថា អ្នកណានៅកង១១នៅទៅ អ្នកណានៅកង១៣នៅទៅ ហៅថាអ៊ីចឹងទៅណ៎ ។ ហ៎! ឥឡូវកង១៣ចេញទៅស្ទូង យើងទៅៗ ។ ហ៎! ថ្ងៃនេះកង១៣នៅកាប់ព្រៃទៅ កង១២ទៅស្ទូងទៅ វាអ៊ីចឹង ។

សុជាៈ អ៎! អានេះគ្រាន់តែយើងមានជាកងទេ តែការធ្វើការ ការហូបចុកដូចគ្នា ធ្វើជាមួយគ្នា?

ថុនៈ នឹងហើយ ។

យ៉ាងៈ ចុះអ៊ំមានចាំទេ ប្រធានកងប្រធានអី?

ថុនៈ ទុកជានេះ ក៏វាមិននេះដែរ អេ! ខ្ញុំនៅព្រែកញ្ញៅមានមីមួយនោះឈ្មោះ មីរី ប៉ុន្តែមីនឹងវាអាពតពីដើមណ៎ អូនឯងដឹងទេ ពេល៧៩មកដល់ ខ្ញុំជួបទាហានក្រាំងទៃនោះ វាទៅប៉ៃលិនវាមកដល់វាចាញ់ វាសុំខ្ញុំស៊ី ខ្ញុំបបរឲ្យស៊ី ខ្ញុំនឹកឃើញថាកូនខ្ញុំបាត់ អ្នកណាខូត់ បើមានលទ្ធភាព ខ្ញុំជួយចិញ្ចឹមវា ដល់ហើយវាថា អ៊ំ ខ្ញុំមិនដឹងមានអីសងគុណអ៊ំឯងអីទេ អ៊ំឯងមានស្គាល់អាពតណាធ្វើបាបអ៊ំឯងទេ ខ្ញុំបាញ់ចោលឲ្យ ។ អូយ! ឆាប់ហើយអានេះម៉េចអ្ហែងធ្វើអ៊ីចឹង អញឈប់ឲ្យអ្ហែងស៊ីបបរអញហើយ បើអ្ហែងនិយាយអ៊ីចឹងនោះ ដល់ហើយ ថ្ងៃមួយគេបុណ្យនៅកន្ទួតនេះ គេបុណ្យតាំងពិពណ៌នោះណ៎ ស្រាប់តែខ្ញុំឃើញនារីអាពតនឹង ។

យ៉ាងៈ ឃើញប្រធានកង១៣នឹង?

ថុនៈ នឹងហើយ ស្រាប់ខ្ញុំឃើញថា ខ្ញុំថា មីនេះនៅអាពតជាមួយអញតើ មីអូនអើយឈ្មោះអាពេជ អាមាស ខ្ញុំថា អាពេជ មីនេះនៅអាពតជាមួយអញ ម៉ោះអញដេញមើលវាបន្តិច វានៅឯណាឥឡូវវី តាំងពីអន្លក់នឹងវាបាត់វារហូត រកវាអត់ដែលឃើញទៀត ។ ហើយពួកអាទាហាននឹងវាថាអ៊ីចឹងណ៎ា វាថាខ្ញុំមិនដឹងបានអីសងគុណអ៊ីឯងទេ អ៊ីឯងល្អជាមួយខ្ញុំណាអ៊ំ តែវាញាក់ទទ្រើក មកពីប៉ៃលិនណ៎ា ដើរមករកសុំបបរ សុំអីស៊ី ខ្ញុំអាំងត្រីបបររៀបចំឲ្យវាស៊ី ហើយវាអត់មានអីសងគុណខ្ញុំ វាថាអាណាធ្វើបាបអូនឯងកាលអាពត ខ្ញុំបាញ់ចោលឲ្យ ខ្ញុំថាអ្អែងមកសងគុណអញអ៊ីចឹង អញអត់ចូលចិត្តជាមួយទេ អញអត់ទៅសងគុណអីជាមួយអ្អែងទៅបាញ់គេចោលអ៊ីចឹងទេ ។ មីស្អីដែលយកអីវ៉ាន់មីប្អូនខ្ញុំយកមកឲ្យនៅត្រពាំងបកតើ ខាងត្បូងភូមិខ្ញុំនឹង ។

យានៈ ចុះអ៊ំកាលជំនាន់ហ្នឹង រី ធ្វើបាបយ៉ាងម៉េចខ្លះ?

ថុនៈ ខ្ញុំគេធ្វើបាបណ៎ាអូន មិនមែនអត់ទេ ។

សុជាៈ ឲ្យធ្វើការយ៉ាងម៉េចមីង?

ថុនៈ ឲ្យធ្វើការស្ទូង ដក ។

សុជាៈ ហើយធ្វើការវាធ្ងន់ធ្ងរទេ វាដូចថាខុសពីក្រុមផ្សេងទៀតទេ?

ថុនៈ នេះ ស្នាមគេវាយខ្ញុំ ។

សុជាៈ ថីបានវាយ ។

ថុនៈ កាលហ្នឹងមិនដឹងខុសរឿងអីទេណ៎ាអូន មីវី នឹងអ្នកវាយខ្ញុំ ។

សុជាៈ វាយនឹងអី?

ថុនៈ កាលហ្នឹងមិនដឹងវាយនឹងអី ខ្ញុំភ្លេចហើយមិនដឹងនឹងឈើ មិនដឹងនឹងអី នេះ ស្នាម នឹងវាយខ្ញុំនៅស៊ីងជ្រៅ រៀបទងជំឡូងអត់ស្អាតឬស្អីទេកាលហ្នឹង ទៅកាត់ទងជំឡូងនៅវត្តក្រពើហារ ហើយយើងមកដាំនៅខាងលិចភូមិណ៎ាអូន អាទួលខាងលិចនឹងសុទ្ធតែទួលជំឡូង ។...ពីដើមចិត្តឆេវឆាវណាអូន នឹកឃើញថាបើមានអាពត គេឲ្យកាប់ក៏កាប់ដែរ តែឥឡូវដល់ចូលរៀនធម៌រៀនអី ខ្ជិលសងទៅគេ កម្មរបស់យើងវាប៉ុននឹង ។

សុជាៈ ចុះមីងមានដែលឃើញ រី នឹងទៅប្រជុំជាមួយថ្នាក់លើទេ?

ថុនៈ អត់ យើងនៅជាប់គុកហើយនឹង ទោះជាទៅប្រជុំគេប្រាប់យើង ។

សុជាៈ ចុះដែលឃើញ រឺ ទៅទេ?

ថុនៈ ពួកអាអស់នឹង បើវាមកប្រជុំវាប្រជុំជាមួយអាដូចនឹង វាប្រជុំជាមួយអាណា បើក្រុមវា នឹងហើយ ។

សុជាៈ ដែលបាត់ពួកនឹង មកទេ?

ថុនៈ គេមកប្រជុំមកអីតើ ។

សុជាៈ ចុះដល់ពេលមកប្រជុំ ទៅវិញគេអនុវត្តន៍យ៉ាងម៉េច?

ថុនៈ គេអត់មានប្រជុំអីទេ ។

យានៈ ចុះអ៊ំមានដឹងថាពីលើ រឺ នឹងមានពីណាទៀត?

ថុនៈ អត់ដឹងទេអូន ។

សុជាៈ ចុះអ្នកគ្រប់គ្រងនៅកន្លែងមីងនឹង ដូចថានៅអន្លង់គងអី អ្នកផ្សេងៗទៀតក្រៅពីមីងនឹង?

ថុនៈ មនុស្សប្រុស មនុស្សស្រីដូចថាពួកអាពតគេនឹងអូន គេគ្រប់គ្រងយើង តែយើងមិនចាំគេ ទេ មិនយកចិត្តទុកដាក់នឹងចាំនឹងត្រូអីគេផងអូន ។

សុជាៈ ដែលឃើញ រឺ ឃើញអីនឹងមកទេ?

ថុនៈ អត់ទេ មីរី នឹងវានៅស៊ីងជ្រៅទេ ។

សុជាៈ តែដែលឃើញ ឌុច អីដើរមកកន្លែងមីងទេ?

ថុនៈ អត់ទេ ទាល់តែថ្ងៃយួនចូល ខ្ញុំរត់ទៅនឹង ទៅជាមួយគេនឹងតែម្តង ឃើញតែម្តង ។

សុជាៈ អ៊ីចេះមួយទៀត មីងនិយាយដំបូង កំពុងតែសម្រាកយប់នឹង គេមកចុចពិលយកទៅ ហើយនឹងពេលមីងនៅព្រៃសរ នៅអន្លង់គងនឹង?

ថុនៈ នឹងហើយនៅអន្លង់គងនឹង យើងដេកដុះអីចឹង តម្រៀបគ្នា ចល័តដូចថាមកពីណាៗមក គ្រប់គ្នាអីចឹងទៅណា យើងមកដេករួមគ្នាក្នុងមុងទាំងអស់គ្នាទៅ ដល់ពេលយប់ឡើងគេមក គេសយកទៅ ។

សុជាៈ ចុះមានដឹងថា ពួកនឹងគេយកទៅណាទេ?

ថុនៈ អត់ដឹងយកទៅណា ។

សុជាៈ ចុះក្រោយមកទៀត?

ថុនៈ នៅនឹងយូរៗទៅ ដល់យូរៗយើងបែកយួនចូលមកនឹង រត់បណ្តោយទៅ ។

សុជាៈ ចុះក្រោយពីបែកយួននឹង មានដែលជួបមុខពួកនឹង?

ថុនៈ អត់លើង មិនដែលជួប ខ្ញុំឆ្ងល់មនុស្ស ។

សុជាៈ មីងសន្និដ្ឋានថា អ្នកដែលគេយកទៅនឹង គេយកទៅណាទេ យកទៅសម្លាប់ឬក៏យកទៅកន្លែងផ្សេង?

ថុនៈ ខ្ញុំថាគេយកទៅសម្លាប់ ។

សុជាៈ មីងសន្និដ្ឋានថាគេយកទៅសម្លាប់នៅឯណា?

ថុនៈ ខ្ញុំថាមានឯណាក្រៅពីបឹងជើងឯកទេ ។

សុជាៈ អ៊ីចឹងបានន័យថា បឹងជើងឯកនឹង ការមកយកមនុស្សយកអីនៅកន្លែងមីងធ្វើការ មិនអ៊ីចឹងអ្ហែស?

ថុនៈ នឹងហើយ ។

សុជាៈ នៅអន្លង់គង?

ថុនៈ ចាំ!

សុជាៈ ហើយមីងថានៅអន្លង់គងនឹងក្រោមការបញ្ជារបស់ ឌុច?

ថុនៈ នឹងហើយ ។

សុជាៈ អ៊ីចឹងបានន័យថា ការយកមនុស្សចេញពីអន្លង់គងនឹងទៅ ឌុច នឹងដឹងទេ?

ថុនៈ ឥឡូវខ្ញុំឧទាហរណ៍ប្រាប់អូនឯងថាអ៊ីចេះ កាលដែលយើងរស់នៅជាមួយ ប៉ុល ពត ដែលគេយកទៅនឹងណាំ យើងមិនដឹងថាគេយកទៅណាទេ ដូចខ្ញុំប្រាប់អូនឯងថា អ្នកឯងទៅអ្នកឯងដឹង ចាំយើងទៅយើងដឹង ។ កាលជំនាន់អាពត យើងមានទៅសាកសួរឯណាបាន សួរតែប្អូនខ្ញុំដែលវាជំនាន់ប្អូនឯង សួរថា មិត្តឯងយកមនុស្សទៅណាំ? ហ៊ានសួរគេអ៊ីចឹង? មិនហ៊ានទេ បានខ្ញុំប្រាប់ថា អ្នកណាទៅអ្នកនឹងដឹង យើងនិយាយតែប៉ុណ្ណឹងចប់រឿងហើយអូន ព្រោះខ្ញុំកោងតែរស់អាត្មា ។

សុជាៈ ចុះមីង ដូចនៅកន្លែងមីងនៅឋាមពលមីងទើបតែបែក៧៥នឹងក៏ដោយ មីងមកនៅអន្លង់គងក៏ដោយ មីងដែលឮគេថា គេចាត់ទុកពួកអ្នកធ្វើការជំនាន់ លន់ នល់ ដូចជាមន្ត្រីរាជការ ជាប៉ូលីស ជាទាហាន ជាលោកសង្ឃអី កាលណាអ្នកណាជាប់ជិតជាមនូវប្រវត្តិរូបទាំងអស់

នឹង ត្រូវបានគេយកទៅសម្លាប់ ធ្វើទារុណកម្ម មីងមានដែលពុទេ មានដែលដឹងទេរឿងនឹង កាលពីជំនាន់ក្រោយ៧៥នោះ?

ថុនៈ អត់ទេ ៗ

សុជាៈ ចុះដូចថាគេហៅកូនមីងទៅសួរនាំ?

ថុនៈ អើ! អានឹងគេហៅសួរកាលយើងទើបតែបែកភ្នាមៗមួយថ្ងៃពីរនឹង ៗ

សុជាៈ នឹងហើយអាភ្នាមៗមួយថ្ងៃពីរនឹង គេចេញនយោបាយ?

ថុនៈ អត់ទេ គេគ្រាន់តែថា អាភ័ណ្ឌ អ្អែងហៅប៉ាអ្អែង ហៅប៉ាឬហៅពុកហៅម៉ាក់ ៗ អត់ទេ ខ្ញុំហៅពុក ហៅម៉ែ ក្រវិលកូនខ្ញុំអា៩ហ៊ុនម្នាង គេដោះឲ្យវាខ្ចប់នឹងជាយក្រមាឲ្យយកមកឲ្យខ្ញុំផង ៗ

សុជាៈ ចុះនៅម្តុំកន្លែងមីងធ្វើការ ទោះបីនៅកន្លែងណាដូចខ្ញុំនិយាយម៉ិញអ៊ីចឹង នៅកន្លែងឋាមពលក៏ដោយ នៅអន្លង់គង មានដែលគេចោទថា អ្នកឯងជាប់ខ្សែសេអ៊ីអា កាហ្សេបេ ជាគិញខ្សែក្បត់អីដូចមីងអ៊ីចឹង ដែលជាប់ខ្សែក្បត់ពី កុយ ធួន មកអ៊ីចឹង មានដែលគេនិយាយថាអ្នកដែលជាប់ត្រូវបានគេយកទៅធ្វើបាប យកទៅសម្លាប់ទេ?

ថុនៈ អត់ទេអូន គ្រាន់តែថា ឧទាហរណ៍អ៊ីចេះ ខ្ញុំប្រាប់អូនឯង ឧទាហរណ៍ឥឡូវគេប្រើយើងណាមីងឯងទៅ... សាលខ្ញុំអត់បានមកទេ សាលគេកាត់ទោសស្អីគេនោះដំបូងបង្អស់ កាត់ទោសនៅស្តាតនោះ?

សុជាៈ ជំនាន់ណា?

ថុនៈ ជំនាន់អាពតយើងបែកហើយនោះ ៗ

សុជាៈ ចាន់ ចក្រី?

ថុនៈ អើ! នឹងហើយ មុនគេបង្អស់ អានឹងគេសុទ្ធតែមកធ្វើមេទិញ គេមិនសម្លាប់គានឹងចោលកាលហ្នឹងជ្រាប ជ្រាបហើយដល់ពេល ខ្ញុំអត់ទាន់ជាប់គុកទេកាលហ្នឹង ដែលគេសម្លាប់សោ ភីម នឹងក្រោយទេ ៗ ទ័ព សោ ភីម កាលណាមក ស្រករៗអូនឯង គេមានក្រមាលឿង កាលហ្នឹងដូចជាមិនទាន់មកទេ ខ្ញុំភ្លេចដែរ ៗ គេសួរខ្ញុំថា អ៊ីគេក្បត់ឯណោះ ម៉េចគេយកយើងមកវាយចោល វាសួរខ្ញុំថាអ៊ីចឹងណា៎ ៗ ខ្ញុំសួរថា អ្នកណាគេក្បត់អាអូន?

ចុះខ្ញុំអត់ដឹង ។ ខ្ញុំកូនចៅ សោ ភឹម តិចថា សោ ភឹម ក្បត់ គេយកខ្ញុំមកវាយចោលអ៊ីឯងមើល ។

សុជាៈ អ៊ំ! ម្នាក់នឹងមកពីបូព៌ា?

ជុនៈ នឹង ។

សុជាៈ ជីបានអ៊ំដឹងថាគេមកពីបូព៌ា?

ជុនៈ ខ្ញុំអត់ដឹងទេ តែដូចថាធម្មតា ល្ងាចនឹងមកអ៊ីចឹង គេឲ្យដាំបាយឲ្យស៊ីពីរបីគោនអ៊ីចឹង ដល់ល្ងាចឡើង បែបយប់ឡើងគេយកទៅវាយចោលអស់ទៅក៏មិនដឹង ។ តែអាពួកនឹងវាប្រាប់ខ្ញុំណា៎ អាពួកដែលវាមកនឹងណា៎ ។ គេដាំបាយឲ្យស៊ីនៅភ្នំពេញនឹង ស៊ីហើយបានគេដឹកយកទៅតទៀតណា៎ តែគេយកទៅសម្លាប់នៅកន្លែងណាខ្ញុំអត់ដឹងទេ ។ ហើយដល់ហើយវាថាអ៊ំខ្ញុំឆ្លល់ដល់ហើយ គេក្បត់ម៉េចគេវាយខ្ញុំចោលណ៎ា ។ ខ្ញុំសួរថា អ្នកណាគេក្បត់? អ៊ំឯងអត់ដឹងទេ សោ ភឹម ក្បត់ គេវាយយើងចោល ។

សុជាៈ កាលហ្នឹងឆ្នាំណា? មីងនៅឯណា?

ជុនៈ កាលហ្នឹងខ្ញុំមិនដឹងនៅឯណា ខ្ញុំភ្លេច ។

សុជាៈ កាលហ្នឹងចេញពីជំរាមពលហើយអ្ហេស មកនៅអន្លង់គងនេះហើយ?

ជុនៈ កាលហ្នឹងបែបចេញមកពីជំរាមពលហើយ តែមិនដឹងខ្ញុំនៅឯណាព្រោះខ្ញុំភ្លេច ។

សុជាៈ ព្រោះនិយាយទៅ សោ ភឹម នឹងក្រោយគេ ចុង៧៧ ដើម៧៨ហើយ ព្រោះដែលគេចាប់មីង ដែលគេចោទប្ដីមីងថា ជាប់ខ្សែ កុយ ធួន នឹងអានឹង៧៦, ៧៧ ។ អ៊ីចឹងមីងជួបពួកគាត់នឹងនៅម្ដុំណា មីងមានចាំទេ? ជួបពួកមកពីបូព៌ានឹងណា៎?

ជុនៈ អាពួកក្រមារាងល្អៀងៗនឹងណា៎ តែមិនដឹងនៅឯណា ខ្ញុំភ្លេចហើយ ។

សុជាៈ តែមីងជួបបានប៉ុន្មានដង?

ជុនៈ ជួបបានម្ដង ។

សុជាៈ ហើយដាំបាយ ដាំអី?

ជុនៈ នឹងហើយ គេដាំបាយឲ្យស៊ី កាលហ្នឹងបែបនៅវត្តក្រពើហារ ម្ដុំនឹង ។

សុជាៈ ច្រើនទេ មកគ្នាប្រហែលចំនួនប៉ុន្មានទៅ?

ជុនៈ គ្នាមកច្រើនៗដែរនឹងណា៎ ហើយខ្ញុំអត់ស្គាល់គេទេអូន ។

សុជាៈ ដាំបាយឲ្យហូបបានម្តង?

ជុនៈ នឹងហើយ ពួកពិការក៏នៅនឹងដែរ ដែលពួកពិការយើងនិន្នាការ វាជាប់គុកដែរណាអូន វានៅនឹងទាំងអស់ មានប្រពន្ធមានកូននៅនឹង ។

សុជាៈ សុទ្ធតែប្រុសៗ មានស្រីៗដែរ?

ជុនៈ ប្រុសៗ ។

សុជាៈ សុទ្ធតែទ័ពតែម្តងពួកនឹងអ្ហេស?

ជុនៈ នឹងហើយ ពួកនឹងសុទ្ធតែទ័ពហើយ ។

សុជាៈ ចុះមានដែលមានអ្នកណាជាខ្មែរកាត់យួន កាត់ចិន ចាមអីគេចាប់ទេ?

ជុនៈ ខ្ញុំអត់ដឹងទេ កាលហ្នឹង ខ្ញុំអត់ដែលបាននៅជាមួយចាមជាមួយអីផង ។

សុជាៈ ក្នុងអគ្គភាពរបស់មីងអត់ដែលមានទេ?

ជុនៈ អត់មានទេ ។ មានចាមមួយ កាលពី៧៥គេឲ្យចាមទៅធ្វើដាយឲ្យយើងនោះ ។ ធ្វើហើយគេបញ្ជូនទៅ មិនដឹងបញ្ជូនទៅណាទៀត ។

យាង: ពេលដែលគេចាប់អ៊ំទៅ ស-២១ មិនគ្រប់គ្រងដោយ ឌុច ។ ហើយហេតុអីបានជាគេបញ្ជូនមកអន្លង់គង? អ៊ំថាអន្លង់គងជាសាខារបស់គេ?

ជុនៈ យល់ឃើញថាអ៊ីចឹងតែម្តង ។

សុជាៈ អ៊ីចឹងបានន័យថា អ្នកទោស ឬអ្នកដែលនៅក្នុងកង១១, កង១២, កង១៣ ដែលត្រូវគេហៅចេញពីអន្លង់គងនឹង តើអ៊ំយល់ថា មានការបង្គាប់បញ្ជាមកពីលើដែរ ឬក៏?

ជុនៈ មិនដឹងជាមកពីណា ខ្ញុំអត់ដឹងដែរពេលនឹង ព្រោះថា កង១១, ១២, ១៣ វានៅក្រោមការគ្រប់គ្រងរបស់អាមួយនៅអន្លង់គងទាំងអស់ ដឹងទេ ។

យាង: អាមួយណា?

ជុនៈ មិនដឹងឈ្មោះអាអី ខ្ញុំភ្លេចឈ្មោះអានឹងទៅ អានឹងខ្ពស់ខ្មៅ ។ និយាយរួមអាអូន ខ្ញុំមកជាប់គុកនៅអន្លង់គងនៅអី ឥឡូវនេះខ្ញុំរកមនុស្សដែលនៅជាមួយគ្នាវាអត់ឃើញ វាអត់ស្គាល់មនុស្សម្នាក់សោះណា៎ ហើយនិយាយពីដើងដើរ បុណ្យណាក៏ខ្ញុំអត់សូវកំបាំងដែរ ។ ឥឡូវនិយាយរួម ឧទាហរណ៍ថាពេលខ្ញុំទៅបញ្ចុះសីម៉ានៅវត្តព្រែកសំរោងនេះ ខ្ញុំទៅកាន់ទិសសីម៉ាភប់យប់ ហើយខ្ញុំណា៎អូន កាលពីខ្ញុំបែកអាពាត មនុស្សដើរ១០ ខ្ញុំមើលមុខទាំង១០

ណា៎ មែនតើ ខ្ញុំអន្ទុយសម្ងឹង ក្រែងប្លែកមុខ ប្តីខ្ញុំមកអីអ៊ីចឹង។ មើលមនុស្សដើរទៅណាខ្ញុំមើល ខ្ញុំដើររកកូនខ្ញុំណា៎ អូសពោតពីច្បារអំពៅដល់ភ្លឺដល់ផ្ទះស្មោរលក់ បានតែបីដីប្អូនដីដើររកកូនម្តង ដើររកអស់ មកអូសពោតលក់ទៀត បានលុយដើររកកូនទៀត។ ខ្ញុំដើររកកូនខ្ញុំ តាំងពីមន្ទីរបាត់ដំបង អាមន្ទីរធំៗ ខ្ញុំទៅជួបគ្រូគេ គ្រូថា អ៊ំអើយម៉ោង១១ពេលញ៉ាំបាយចាំអ៊ឹងឯងមក។ ដល់ពេលខ្ញុំឡើងទៅ គេថា កូនៗមានម៉ែយើងមកពីខេត្តកណ្តាលកូនឯងមើលមុខ ហើយបើកូនណាស្គាល់ម្តាយកូនឯង មិត្តឱបម៉ែចុះ ខ្ញុំដើរគ្រប់ជួរទាំងអស់ គ្មានមុខអាណាមួយថាម៉ែវាម្តងទេ។

យាង: ដើររកកូនពីរនាក់នឹង?

ថុន: ចា៎! នឹងហើយ ឈ្មោះ សុភ័ណ្ឌ, ឈ្មោះ សុភ័ស្ត នឹង និយាយពីអូនអើយ ប្រាំងចោទឬស្សីក្រាំង, ត្រលោហាទិល ខ្ញុំរត់រកកូនខ្ញុំកាត់គ្រាប់ដូចរត់រកអីអ៊ីចឹង ខ្ញុំខ្លាចលោគេបង្ហូរកូនខ្ញុំទៅនឹងណា៎។ គេរត់ទៅនឹង គេថា អ៊ូ៎!កុមារចុះពីលើភ្នំណា។ បាយម៉ាកាម៉ែលវីងខ្ញុំដើរទៅដល់ភូមិគរណា៎ ត្រលោហាទិលណា៎ ខ្ញុំកាត់ទៅចាំ អន្ទុយសម្ងឹង យប់ខ្ញុំដើរមកវិញខ្ញុំថាអាណាបាញ់ផាប់ៗទៅ។ ខ្ញុំផ្តាំគេថា ប្រាប់ម៉ែអញផង អត់ទៅទេ ទាល់តែអញរកកូនឃើញបានអញទៅ បើអញរកអត់ឃើញ អញអត់ទៅទេ។

យាង: ចុះហេតុអីបានអ៊ំទៅទៀត បើអ៊ំរកឃើញអាក្រណាត់ចងមុខអី?

ថុន: ចា៎! អានឹងអត់ទាន់មកដល់ផ្ទះទេ ខ្ញុំនៅដើររកកូនខ្ញុំពេញភ្នំណា៎។ កូនប្រុសខ្ញុំមួយដែលនៅជាប់ដៃនឹងណា៎ ទៅស្លាប់នៅប្រាំងចោទណា៎។ ហើយបើមីស្រីមួយនៅជាប់នឹងខ្លួនមួយទៀតណា៎ អានឹងពួកមិត្តអូសពីដៃខ្ញុំបាត់ដែរ។

យាង: គេអូសយកទៅណា៎?

ថុន: បាត់។ កូនខ្ញុំទាំងអត់បាត់បី ផាប់មួយ។

សុជា: មីងខ្ញុំចង់សួរថា គេមកចាប់មនុស្សពីអន្លង់គងនឹងទៅ គេច្រើនតែមកចាប់ពេលយប់ទេពេលថ្ងៃអត់មានទេ?

ថុន: គេមកយកយប់។

សុជា: ហើយអ្នកណាគេមកចាប់នឹង?

ថុន: អត់ដឹង។

សុជាៈ អត់ឃើញអីទេ?

ថុនៈ អឺ!

សុជាៈ ឃើញតែមកកេះទៅៗ ហើយយើងក៏អត់មានគាមមើលអី?

ថុនៈ អត់ទេ អត់មានងើបចេញទេ រឹតតែសំងំថែមៗ

យានៈ ចុះនៅក្នុងក្រុម១៣របស់អ៊ីនឹងមានបាត់គ្នាច្រើនទេ?

ថុនៈ អត់សូវដែរអូន ដូចថាសុទ្ធតែអ្នកខ្លាចគេណា។

យានៈ អត់សូវ តែមានបាត់ខ្លះ?

ថុនៈ មាន តែយើងមិនដឹង ដូចថាស្រុកគេណ៎អូន ចុះច្រឡូក មើល ដូចខ្ញុំថាមួយគោកគ្រប មានតែខ្ញុំមួយ ហើយខ្ញុំទៅស្គាល់អ្នកណាទៀត ម៉្លោះហើយឃើញមុខគ្នា ដូចថា ខ្លះគ្នាទើប តែយកមកពីរបីនាក់ ស្នាក់អ៊ីចឹងទៅ តិចៗគេបាត់ទៅវិញទៅ មិនដឹងគេបាត់ទៅណា ឧទាហរណ៍គេថា មិត្តរៀបចំអីវ៉ាន់ទៅ មិត្តទៅស៊ីងជ្រៅវិញ អ៊ីចឹងទៅ ហ៎! អ្នកស៊ីងជ្រៅ មិត្តត្រូវរៀបចំអីវ៉ាន់មកនេះវិញ អ៊ីចឹងវាច្រឡូកបូកគ្នាអ៊ីចឹងណ៎ ម៉្លោះហើយយើងទៅចាំ មើលអី យើងរង់ចាំតែថ្ងៃស្លាប់ដូចតែគ្នានឹង សំណាងមានហើយដែលបានរស់មកប៉ុណ្ណេះ ណ៎ អ៊ីចឹងបានថា អូនខ្ញុំសរសើរសំណាងៗ អូន ដល់ខ្ញុំដើររកគ្រូទាយ និយាយពីខ្ញុំប្រាប់ អូនឯង ទាយត្រូវ បើថាកូនរស់ដាក់លុយថែម បើថាកូនខ្ញុំងាប់យកលុយដាក់ក្នុងហោប៉ៅ ខ្ញុំវិញណ៎ ខ្ញុំអត់ឲ្យទេ។ ខ្ញុំដើររកកូននឹង ខ្ញុំដើររកសោះ អស់កន្លែងរកហើយ។ ម៉ាសាលា ខ្ញុំដើរដូចឆ្កួត ខ្ញុំប្រាប់អូនឯង ដើរបង្ហាញមុខក្មេងក្រែងលោកូនឯងនៅហ្នឹង វាស្គាល់ណា គ្មានអ្នកណាមួយវាថាយើងម៉ែវាម្ដងផង អត់ បានខ្ញុំចេះតែសន្និដ្ឋានថា កូនខ្ញុំងាប់នៅបឹង ជើងឯកហើយ បានជាខ្ញុំខំទៅបង្សុកូលរាល់តែដង។

សុជាៈ បឹងជើងឯកនឹងនៅក្រោមស-២១ទេ?

ថុនៈ អត់ដឹងទេអូន។

សុជាៈ នៅក្រោមការគ្រប់គ្រងរបស់ ឌុច ដែរ?

ថុនៈ អត់ដឹង។ ដឹងតែឃើញខ្មោចថ្ងៃយើងហើយចប់តែម្ដង។

សុជាៈ ចុះអាពេលដែលគេចាប់មីង ហើយគេមកធ្វើប្រវត្តិរូប ថតនេះ តើគេថតនៅឯណាអីឯ ណា?

ថុនៈ  អន្លង់គង ។

សុជាៈ  ហើយអ្នកដែលគេមកធ្វើមកសួរនឹង  តើគេនឹងអ្នកនៅនឹងតែម្តង  ឬក៏គេមកពីចំងាយគេមក ធ្វើហើយ  គេទៅវិញ?

ថុនៈ  គេនៅនឹង ។  គេគ្រាន់តែដឹកយើងមក  គេទម្លាក់យើងគេទៅវិញហើយ ។

សុជាៈ  គេអ្នកធ្វើ?

ថុនៈ  ចាំ!  ហើយអាអ្នកនៅទីនេះហើយ  គេធ្វើយើង  គេហៅឈ្មោះអ៊ីចឹងហើយ  ដូចថា  កែប ថុន អ៊ីចឹងគេធ្វើប្រវត្តិរូបយើងទៅ ។

សុជាៈ  គេមានប្រាប់ថាម៉េចបានជាគេធ្វើប្រវត្តិរូបទេ?

ថុនៈ  អត់ ។

យានៈ  អ៊ីចឹងពេលដែលកូនអំពីរនាក់ឈ្មោះ  សុភ័ណ្ឌ, សុភ័ស្ត  នឹង  គេចាប់មកពីអន្លង់គងដែរ?

ថុនៈ  អត់ទេ ។

យានៈ  ចាប់មកពីកន្លែងផ្សេង?

ថុនៈ  បាត់ឈឹងតែម្តង  តាំងពីខ្ញុំចេញពីភ្នំពេញខ្ញុំបាត់កូនរហូត ។

សុជាៈ  ចុះកូនពីរនាក់?

ថុនៈ  អានឹងកូនជាប់នឹងខ្លួន  ងាប់អស់ដែរនឹង ។

សុជាៈ  ស្លាប់ដោយសារអីគេ?

ថុនៈ  អាមួយកើតបុសកន្លែងនេះ  ងាប់នៅប្រាំងចោទ  មីមួយទៀតបាត់ ។

សុជាៈ  រត់ទៅព្រៃ?

ថុនៈ  ចាំ!  រត់ទៅព្រៃ  ដោយទាំងពីរនឹងទៅ  ស្លាប់ទាំងពីរនឹងទៀត ។

សុជាៈ  ស្លាប់នៅក្នុងអាពតនឹងទេ?

ថុនៈ  នឹងហើយ ។

សុជាៈ  ចុះប្តីមីង  ក្រោយមកពេលដែលមីងទៅដល់វត្ត  ទៅដល់អន្លង់គង  ស៊ីងជ្រៅនឹង  មីងមាន បានដឹងដំណឹងពីប្តីមីងទៀតទេ?

ថុនៈ  អត់  ឈឹង  ។

សុជាៈ  ចុះក្រោយមកទៀត  ក្រោយ៧៩មក?

ថុនៈ ឈើង ។

សុជាៈ ចុះមីងថាបានឃើញរូបថតគាត់នៅទួលស្លែងឯណាណោះ?

ថុនៈ ចាំមើល នឹងប្អូនថៃថាចនឹងប្រាប់ខ្ញុំណា៎ គេនៅជិតផ្សារកណ្ដាល ស្រាប់តែខ្ញុំជួប ជួបទៅ គេប្រាប់ខ្ញុំថា កាលហ្នឹងគេផ្ដាំតាមពីណាទេ ថា ផ្ដាំទៅ បងថុន ផង ថាឲ្យទៅមើលរូបថត តាហ៊ិន នៅគុកទួលស្លែងណា៎ លេខ៤៧ ថារូបថត តាហ៊ិន, តាអន, តាសុខ នឹងនៅជិតៗគ្នា គេប្រាប់ថាអ៊ីចឹង ។ ខ្ញុំធ្លាប់នាំពួកអាមេរិកបងប្អូនខ្ញុំមកចូលមើលណា៎ តែខ្ញុំចូលទៅ ដូចថាខ្ញុំទទួលមិនបានតែខ្ញុំចូលទៅ ដូចថា ស្លុត ។ ខ្ញុំចូលទៅតាំងពីនេះណា៎ ចូលទៅស្លុតៗ ខ្ញុំលែងចូលរហូត ខ្ញុំអត់ចូលទេ ។

យ៉ានៈ ចុះកាលពេលអ៊ីចូលទៅកាលដំបូងនោះ ឃើញរូបថតគាត់នៅនឹងទេ?

ថុនៈ អត់ទេ ខ្ញុំអត់បានមើលផង ។ គេប្រាប់ខ្ញុំទេ ខ្ញុំអត់បានឃើញផ្ទាល់ទេ ។ ដល់ក្រោយឡើងទៀត ខ្ញុំទៅផ្ទះ បងថាច នឹងទៅសួររកកូន គេថាគេបានជួបកូនគេណា៎ ព្រោះគាត់បាត់កូនពីរដែរ បងថាត នឹង បាត់ អាគង់ មួយនិង អាអាថ ។ ដល់ខ្ញុំសួរ បងថាត ថាអត់មានឃើញអីទេ ម៉ែភ័ណ្ឌ យើងវាចប់រឿងហើយ តែគេនៅក្មេងដែរ ។

សុជាៈ មិត្តថាច នឹងគាត់អ្នកធ្វើការនៅឋានមពលនឹងជាមួយមីងដែរអ្ហេស?

ថុនៈ ថាច គេធ្វើឆ្មប ។

សុជាៈ ឆ្មបនៅឯណា?

ថុនៈ ឆ្មប ពេទ្យនៅឋានមពលនឹង ។

យ៉ានៈ ចុះបាត់ មន?

ថុនៈ នឹងហើយបាត់ មន ។ មន នឹងនៅកំពង់ចាម បាត់សូន្យ បើថានឹងខ្ញុំជួបម្ដង អើ ដូចថាមនុស្សចរិតគេឆ្មើងឆ្មៃ គេអត់សូវនេះ ម៉្លោះហើយលែងទៅជួបគេលែងអី ខ្ញុំទៅសួរចង់ដឹងដំណឹងកូនខ្ញុំ ថាគេនឹងជួបកូនណា៎ ដល់ពេលខ្ញុំទៅសួរគេ គេនិយាយដូចថាមិនជាស្និតស្នាលជាមួយគេប៉ុន្មានណា៎ ។ ដល់ហើយ ខ្ញុំគ្រាន់តែសុំសួរ ។

សុជាៈ ប្ដី មីងថាច នឹងឈ្មោះអីគេ?

ថុនៈ ឈ្មោះ សុខ ។ តែមិនដឹងស្អី សុខ ទេ ។

សុជាៈ បាត់នៅក្នុងទួលស្លែងនឹងដែរ?

ថុនៈ បាត់ដែរ បាត់ជាមួយគ្នា ។

សុជាៈ ហើយមានឃើញរូបថតនៅទួលស្លែងនឹងដែរ?

ថុនៈ នឹងហើយ អន្លាល់ដែលប្តីនឹងគេយកទាំងបីនឹង បានគេយកពួកខ្ញុំទាំងបីនឹងមកដែរ នឹងមកថ្ងៃជាមួយគ្នា បីនឹង ។

យាងៈ ចុះ មន នឹងគាត់បាត់ពេលមកអន្លង់គងនឹង?

ថុនៈ ចា៎! មន នឹងមកបែកគ្នានៅអន្លង់គងនឹងតែម្តង ។

យាងៈ អ៎! អ៊ីចឹងគាត់បាត់នៅកន្លែងនឹង?

ថុនៈ មិនដឹងគាត់ទៅណាមកណើ អត់ដឹង ដូចបែកគ្នាអ៊ីចឹងទៅណា៎ ហើយបើ មិត្តថាច នឹងយើងចេះតែធ្វើការជាមួយគ្នា ហើយដល់រត់ទៅ យើងបែកគ្នាដែរ ទើបតែដឹងដំណឹងថា គេឃើញកូនគេ បានខ្ញុំទៅស្រាវជ្រាវរកគេនឹងណា៎ ដល់ទៅៗ គេនិយាយដូចរាង...ខ្ញុំទៅសួរគេតែម្តងនឹង ខ្ញុំលែងទៅជួបគេទៀតហើយ ។

សុជាៈ ចុះក្រៅពីថ្នាក់ដឹកនាំធំៗដែលមីងធ្លាប់ឮឈ្មោះ ធ្លាប់ឃើញ ដូច កុយ ធួន?

ថុនៈ កុយ ឃួន ខ្ញុំអត់ដែលឃើញគេទេ ។

សុជាៈ អត់ដែលឃើញតែមីងស្គាល់ ។

ថុនៈ ចា៎! ឮសូរតែឈ្មោះទេ គណភូមិភាគខត្តរឈ្មោះ កុយ ធួន នឹង ។

សុជាៈ ដូច រ៉ាន់ រិទ្ធ នឹងមីងធ្លាប់ឃើញ ចុះអ្នកធំផ្សេងៗទៀត មីងធ្លាប់ឃើញទេ?

ថុនៈ អត់ដែលទេ ។

សុជាៈ មីងដែលស្គាល់ មានដែលឮឈ្មោះអ្នកធំៗទៀត ដូច ខៀវ សំផន, តាម៉ុក អីមានដែលឮទេ?

ថុនៈ អត់ទេ ។

សុជាៈ អ៊ីចឹងមីងអរគុណច្រើនមីងណា៎ ។ មីងមានអ៊ីបន្ថែមទៀតទេ?

ថុនៈ អត់មានអីក្មួយ ។

សុជាៈ អរគុណដែលរំខានមីង ។

ចប់